# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*ការធ្វើការដោយបង្ខំ ខ្ញុំក៏យល់ថាខុសដែរ មិនមែនថាត្រូវទេ ។*
*ខុសត្រង់ថា យើងឲ្យគ្នាធ្វើហ្នឹង គឺវាខ្លាំងដែរ អីចឹងខ្ញុំក៏មិនយល់ថាត្រូវដែរក្នុងសម័យនោះ។ ឲ្យបង្ខំមនុស្សដែរ តែខ្ញុំក៏នឹកឃើញថា ខាងលើដាក់ផែនការយ៉ាងម៉េច ក៏ធ្វើអីចឹងទៅ មិនហ៊ានថាយ៉ាងម៉េចទេ។*

***-សាក្សី ប្រាក់ យុត***

## *ជំពូកទី១ :* ទិដ្ឋភាពទូទៅ

ចាប់ពីថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១២ ភាគីបានសួរ ដេញដោលទៅកាន់ជនជាប់ចោទ **នួន ជា** សាក្សី **ប្រាក់ យុត** ដែលជាអតីតកម្មាភិបាលថ្នាក់ទាបម្នាក់ក្នុងរបបខ្មែរក្រហម និងសាក្សីមួយរូបទៀត គឺលោក **ឆាំង យុ** ជាអគ្គនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ( *ឌី.ស៊ី.ខេម* ) ។ កាលពីព្រឹកថ្ងៃច័ន្ទ ភាគីសហព្រះរាជអាជ្ញាបានបញ្ចប់ការសួរដេញដោលរបស់ខ្លួនទៅលើលោក **នួន ជា** ។ ក្រោយមក តុលាការបានអនុញ្ញាតឲ្យគាត់តាមដានសវនាការបានពីបន្ទប់សោតទស្សន៍វិញ ។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីជនជាប់ចោទ បានបញ្ចប់ការចោទសួរលើសាក្សី **ប្រាក់ យុត** នៅរសៀលថ្ងៃច័ន្ទ ។ កាលពីថ្ងៃអង្គារ លោក **នួន ជា** បានឆ្លើយតបនឹងសំណួរមួយចំនួនពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងពីសំណាក់មេធាវីប្រឹក្សាក្តីអន្តរជាតិរបស់គាត់ផងដែរ គឺលោក **ម៉ៃខល ផេស្តមិន** ។ ភាគីព្រះរាជអាជ្ញា បានប្រើប្រាស់ពេលវេលាចោទសួររបស់ខ្លួន បន្តពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយឡែកក្រុមមេធាវីការពារក្តីលោក **នួន ជា** និងលោក **ខៀវ សំផន** វិញបានធ្វើការចោទសួរលើសាក្សី **ឆាំង យុ** ។ ភាគីទាំងអស់នឹងបញ្ចប់ការសួរដេញដោលលើសាក្សី **ឆាំង យុ** នៅថ្ងៃច័ន្ទទី៦ ខែកុម្ភៈ ( *សប្តាហ៍បន្ទាប់* ) ។

សប្តាហ៍នេះ អង្គជំនុំជម្រះបានបន្តប្រឈមនូវបញ្ហានីតិវិធីខុសៗគ្នាមួយចំនួនទាក់ទងនឹងការបកប្រែឯកសារ និងលក្ខន្តិកៈក្នុងការជ្រើសរើសឯកសារដែលបានបញ្ចូលនៅក្នុងសំណុំរឿង ក៏ដូចជាដំណើរការបញ្ជាក់ពីយថាភាពនៃឯកសារទាំងនោះ ។ យើងក៏ឃើញមាននូវការព្យាយាមជំទាស់ជាច្រើន ដាក់កម្រិតទៅ

លើសាក្សីដែលបានឆ្លើយប្រាសចាកពីវិសាលភាពសំណុំរឿង០០២/០១ ។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមមេធាវីការពារក្ដីលោក **នួន ជា** បានចោទប្រកាន់ថាមានការជ្រៀតជ្រែកផ្នែកនយោបាយដ៏ក្ដៅគគុក ដែលជាថ្មីម្ដងទៀតបង្កឲ្យមានការព្រួយបារម្ភថាតើពិត ឬយ៉ាងណា ដែលសាក្សីណាម្នាក់បានទទួលរងនូវឥទ្ធិពលមិនល្អអ្វីមួយ មុនពេលចូលមកផ្ដល់សក្ខីកម្ម ។ យើងឃើញការប្រឈមមុខគ្នាយ៉ាងចាស់ដៃនៅក្នុងបន្ទប់សវនាការតាំងពីដើមដល់ចប់ដំណើរការនីតិវិធីសប្ដាហ៍នេះ រវាងសាក្សី និងក្រុមមេធាវីប្រឹក្សាក្ដី ក៏ដូចជារវាងក្រុមមេធាវីការពារក្ដី ជាមួយនឹងអង្គជំនុំជម្រះ។ ចំពោះបរិយាកាសក្នុងបន្ទប់សវនាការវិញ យើងក៏ឃើញមានការសម្ដែងឥរិយាបថតាមលក្ខណៈបុគ្គលរៀងៗខ្លួនតាមរយៈប្រតិកម្មរបស់ពួកគេ តទល់នឹងព្រឹត្តិការណ៍ប្រឈមដែលបានកើតឡើងក្នុងដំណើរកិច្ចសវនាការ ។

## *ជំពូកទី២ :* សេចក្ដីសង្ខេបស្ដីពីការផ្ដល់សក្ខីកម្មរបស់សាក្សី

លោក **នួន ជា** បានផ្ដល់សក្ខីកម្មស្ដីពីគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ក៏ដូចជាការអនុវត្ត ពិសេសទាក់ទងនឹងការបំបិទមិនឲ្យមានការចរាចរក្រដាសប្រាក់ ការបង្កើតសហករណ៍ ការជម្លៀសចេញពីទីក្រុងភ្នំពេញ អត្ថន័យនៃពាក្យៈ *សមាសភាពមិនល្អ ការតស៊ូប្រដាប់អាវុធ* និង*ថ្នាក់ដឹកនាំបក្ស* ។ តាំងពីដើមដល់ចប់នៃសក្ខីកម្មរបស់គាត់ លោក **នួន ជា** ជាញឹកញយបានគូសបញ្ជាក់ថា គាត់ចង់ស្រាយបំភ្លឺនូវកំណត់សម្គាល់មួយចំនួន ដើម្បីជាប្រយោជន៍ដល់យុវជនជំនាន់ក្រោយៗ ។

អ្នកស្រី **ប្រាក់ យុត** ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ដែលបានផ្ដល់សក្ខីកម្មបញ្ចប់ក្នុងសប្ដាហ៍នេះ រីឯលោក **ឆាំង យុ** បានចាប់ផ្ដើមផ្ដល់សក្ខីកម្មស្ដីពីខ្សែចង្វាក់នៃការរក្សាទុកឯកសារមួយចំនួន ដែលមានប្រភពចេញពី *ឌី.ស៊ី.ខេម* ហើយត្រូវបានបញ្ចូលទៅក្នុងបញ្ជីសំណុំរឿង ក៏ដូចជាដំណើរការនៃការរៀបចំដូចម្ដេចខ្លះ ដើម្បីបញ្ជាក់ពីយថាភាពនៃឯកសារទាំងនេះ ។

## ក. ការបន្តការសួរដេញដោលលើជនជាប់ចោទ នួន ជា

ការត្រឡប់ចូលមកផ្ដល់សក្ខីកម្មជាថ្មីម្ដងទៀតក្នុងសប្ដាហ៍នេះ លោក **នួន ជា** បាននិយាយអំពីមូលហេតុដែលនាំឲ្យគាត់បោះជំហានចូលជាសមាជិកភាពនៃបក្សកុម្មុយនីស្ដកម្ពុជា ។ គាត់បានរៀបរាប់ថា តាំងពីគាត់នៅក្មេងវ័យ គាត់មានបំណងចង់ធ្វើការតស៊ូ និងប្រយុទ្ធតទល់នឹងការប្រើអំណាចជិះជាន់ដែលកើតមានក្នុងសង្គមខ្មែរ ។ កាលណោះ គ្រួសារគាត់បានជំពាក់បំណុលគេ ហើយគាត់បានឃើញប្រទេសកម្ពុជាជាប្រទេស "ពាក់កណ្ដាលអាណានិគមនិយម ហើយនិងទាសករ" ។[៣] គាត់បានបរិយាយពីរបៀបនៃការប្រើអំណាចសង្កត់សង្កិនពីអាណានិគមបារាំងលើប្រជាជនខ្លួនធ្វើឲ្យគាត់មានសេចក្ដីរន្ធត់ អាណិតអាសូរ និងមានចិត្តចង់ជួយស្រោចស្រង់ប្រទេសឲ្យផុតពីការជិះជាន់ទាំងនោះ ។ មិនយូរប៉ុន្មាន គាត់ក៏បានបួសជាសាមណេរ (*លោកនេន*) ។ យោងតាមជនជាប់ចោទ បន្ទាប់ពីប្រទេសកម្ពុជាត្រូវបានប្រគល់ខេត្ត*បាត់ដំបង* និងខេត្ត*ស្វាយស៊ីសុផុន* ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រទេសថៃ គាត់បានចាប់អារម្មណ៍ចង់រៀនសូត្រពីប្រទេសថៃ ថាតើគេបានប្រើប្រាស់លទ្ធិកុម្មុយនីស្ដ និងអត្ថប្រយោជន៍របស់វាដូចម្ដេចខ្លះ ។ បន្ទាប់មក លោក **នួន ជា** ក៏បានចូលសិក្សាច្បាប់នៅសាកលវិទ្យាល័យធម្មសាធនៃទីក្រុងបាងកករយៈពេលបីឆ្នាំ ។ ទោះជាយ៉ាងណាក្ដី គាត់បានឈប់ដោយមិនបានចូលរួមប្រលងវគ្គបញ្ចប់ការសិក្សាទេ ព្រោះតែគាត់ជឿជាក់ថា ការ

ចូលរួមក្នុងចលនាតស៊ូសំខាន់ជាង ។ នៅឆ្នាំ១៩៤៦ លោក **នួន ជា** និយាយថាគាត់បានចូលរួមជាមួយនឹងអង្គការ "យុវជនប្រជាធិបតេយ្យថៃ" ដែលស្ថិតក្រោមរចនាសម្ព័ន្ធបក្សកុម្មុយនីស្តថៃ ។ គាត់បានធ្វើការសិក្សាស្រាវជ្រាវពីខ្សែបណ្តោយបក្ស ក៏ដូចជាពីរបៀបដែលថៃជួយដោះស្រាយបញ្ហាសង្គមតាមរយៈលទ្ធិកុម្មុយនីស្ត (*ចូលរួមធ្វើបាតុកម្មប្រឆាំងរដ្ឋាភិបាល ប្រឆាំងការចាប់ចងសាស្ត្រាចារ្យជាដើម*) ។ លោក **នួន ជា** បានបន្តនិយាយពីចំណងទាក់ទងកាលពីឆ្នាំ១៩៥០ ដោយគាត់ត្រូវបានផ្ទេរឲ្យចូលក្នុងបក្សឥណ្ឌូចិន តែគាត់បានអះអាងថា គាត់មិនមានតួនាទីអ្វីពិតប្រាកដទេ ។ ទោះជាយ៉ាងណាក្តី គាត់បានទទួលស្គាល់ថា គាត់ជាបក្ខជនមួយរូបទទួលបន្ទុកផ្នែកអប់រំ ហើយដែលតាមរយៈតួនាទីមួយនេះ គាត់បានធ្វើដំណើរចុះតាមភូមិឃុំជាច្រើន គាត់បានសរសេរកាសែតអប់រំបក្ស និងរៀបចំធ្វើការឃោសនា ។ ក្រោយមកទៀត លោក **នួន ជា** បានត្រឡប់មកកាន់ប្រទេសកម្ពុជាវិញតែម្នាក់ឯង ដើម្បីបន្តការតស៊ូក្នុងប្រទេសខ្លួនវិញ ។ គាត់បានបញ្ជាក់ថា ពេលនោះគាត់បានចូលរួមបម្រើការងារជាមួយបក្សកុម្មុយនីស្តថៃរួចហើយ ហើយគ្រាន់តែមានការជាប់ទាក់ទងគ្នាតាមរយៈបក្សឥណ្ឌូចិនដែលស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាម ។

លោក **នួន ជា** បាននិយាយថា បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុង*ហ្សឺណែវ* ឆ្នាំ១៩៥៤ គាត់បានរៀបចំចលនាកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ជាមួយនឹងបុគ្គលបី ឬបួននាក់ផ្សេងទៀត មានដូចជា **សាឡុត ស** (ប៉ុល ពត) លោកតា **ទូ សាមុត មី ម៉ាញ់** និងអ៊ំរបស់គាត់ឈ្មោះ **ស៊ីវ ហេង**។[៤] ពួកគាត់ បានផ្តើមធ្វើចលនានេះចេញពីទីជនបទមុន ជាក់ស្តែងចេញពី*តំបន់ភ្នំឱរ៉ាល់តំបន់វលោកកងជើង* និង*តំបន់មុំប្រាំបី* ហើយក្រោយមក ក៏ចុះដល់តំបន់ទីទំនាបផ្សេងៗទៀត ។ ជនជាប់ចោទបានពន្យល់បន្តទៀតថា ពួកគាត់បានចាប់ផ្តើមធ្វើការជាមួយអ្នកស្រែចម្ការក្រីក្រ និងបានធ្វើការជួយជ្រោមជ្រែងជាប្រចាំនៅតាមតំបន់ភ្នំនានា ។ គ្រានោះ មានតែមនុស្សមួយក្រុមតូចតែប៉ុណ្ណោះ ហើយពួកគាត់មិនបានបែងចែកតួនាទីជាក់លាក់ណាមួយក្នុងចំណោមបក្ខជនបី ឬបួនរូបហ្នឹងដែរ ។

ចំពោះករណីហស្សនាមដែលគាត់បានប្រើក្នុងអំឡុងពេលប៉ុន្មានឆ្នាំនោះ លោក **នួន ជា** បាននិយាយថា នៅប្រទេសថៃ គាត់បានប្រើហស្សនាម "**រុងឡឺត ឡៅឌី**" ពីព្រោះមានការតម្រូវឲ្យសិស្សខ្មែរដូចជា រូបគាត់ត្រូវបកប្រែឈ្មោះជាភាសាថៃ ។[៥] គាត់និយាយថា គាត់មានឈ្មោះហៅក្រៅមួយចំនួនទៀត តែចុងក្រោយបានសម្រេចយកតែឈ្មោះ "**នួន ជា**" នៅពេលគាត់ត្រឡប់ចូលប្រទេសកម្ពុជាវិញ ។ ជនជាប់ចោទដូចដែលបានចង្អុលបង្ហាញនេះមានឈ្មោះក្នុងបញ្ជីកំណើតគាត់ថា **ឡៅ គឹមឡន** ។

## *ក.១. លក្ខន្តិកៈសម្រាប់សមាជិកភាពបក្សកុម្មុយនីស្តកម្ពុជា*

លោក **នួន ជា** បានផ្តល់សក្ខីកម្មថា គាត់ទទួលបានសមាជិកភាពក្នុងបក្សកុម្មុយនីស្តកម្ពុជាតាមរយៈការសំណូមពរ ហើយដែលសមាជិកម្នាក់ៗត្រូវតែមានការធានាពីបុគ្គលបីរូបផ្សេងទៀត ។ ក្រៅពីភក្តីភាពចំពោះវិន័យបក្ស សមាជិកម្នាក់ៗត្រូវតែបង្ហាញពីជាតិនិយម ស្នេហាប្រជាជន មានសីលធម៌ខ្ពស់ និងមានឆន្ទៈបូជានូវផលប្រយោជន៍ផ្ទាល់ខ្លួនដើម្បីប្រយោជន៍រួម ។ លើសពីនេះទៀត ជាសមាជិកបក្សម្នាក់តម្រូវឲ្យចូលស្បថសច្ចាប្រណិធានចំពោះជាតិ ចំពោះប្រជាជន ចំពោះជួរវិន័យបក្ស ព្រមទាំងជម្រុះឲ្យអស់នូវការគិតពីប្រយោជន៍ផ្ទាល់ខ្លួន ។

ដើម្បីមានតួនាទីផ្សេងៗក្នុងជួរបក្សបាន សមាជិកម្នាក់ត្រូវបង្ហាញនូវភាពស្មោះស្ម័គ្រ សេចក្តីព្យាយាម និងមានឆន្ទៈតស៊ូ ។ ជនជាប់ចោទបានថ្លែងថា បើសមាជិកណាម្នាក់បានកសាងខ្លួនដោយស្មារតីមិនងាករេ បុគ្គលនោះត្រូវបានទទួលឋានៈចាប់ពីថ្នាក់ភូមិដល់ឃុំ ហើយឡើងពីថ្នាក់ស្រុកទៅថ្នាក់តំបន់ មុនពេលក្លាយខ្លួនជាតំណាងភូមិភាគ ។ លោក **នួន ជា** បានបន្តបំភ្លឺថា ចំពោះសមាជិកណាដែលបានទទួលការអប់រំគ្រាន់បើ និងមានឱកាសច្រើនជាងក្នុងការចូលរួមធ្វើសេចក្តីសម្រេចក្នុងជួរបក្ស ។ ការទទួលបានឋានៈ នឹងអាចប្រើពេលមួយទៅពីរឆ្នាំចំពោះសមាជិកណាដែលមានការអប់រំតិច ឬមិនសូវសកម្មក្នុងកិច្ចខិតខំខ្នះខ្នែង ជាមួយការងារបក្ស ។

## *ក.២. ការពន្យល់អំពីតួនាទីរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា*

តាមរយៈសំណួរសួរដោយព្រះរាជអាជ្ញាជាតិ លោក **សេង ប៊ុនឃាង** ជនជាប់ចោទ **នួន ជា** បានបញ្ជាក់ថា នៅឆ្នាំ១៩៥១ គាត់មិនមានការពាក់ព័ន្ធអ្វីជាមួយគណៈមជ្ឈិមទេ ហើយក៏មិនទាន់មានការបង្កើត "គណៈកម្មការ" អ្វីដែរកាលពីជំនាន់នោះ ។ ជនជាប់ចោទបានថ្លែងថា តាំងពីគាត់ទទួលបន្ទុកផ្នែកឃោសនា និងអប់រំមក គាត់ពាក់ព័ន្ធតែទៅការកែសម្រួលខ្លឹមសារកាសែតបក្ស និង "សារព័ត៌មានអ៊ីសារ៉ាក់" ក៏ដូចជាផ្តល់ដំបូន្មាន (បង្រៀន) ដល់សមាជិកបក្សថ្នាក់ភូមិឃុំជាច់ស្រយាលមួយចំនួន ។ លោក **នួន ជា** បានទទួលស្គាល់ថា គាត់បានរៀបចំធ្វើគោលនយោបាយបក្សជាមួយ **ទូ សាមុត** និង **ប៉ុល ពត** ។

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក **បាណាបេ ណេគ្វី** បានសួរសង្កត់ធ្ងន់ទៅលើភារៈផ្សេងៗស្តីពីការដឹកនាំកាលពីឆ្នាំ១៩៦៨ នៅពេលដែលបក្សកុម្មុយនីស្តបានចែកចេញជាពីរផ្នែកៈ ផ្នែកទី១មានទីតាំងនៅខេត្តរតនគិរី ដែលមាន **ប៉ុល ពត** ជាអគ្គលេខាធិការបក្ស រីឯទី២ មានទីតាំង នៅទីក្រុងភ្នំពេញ ដោយលោក **នួន ជា**"ទទួលបន្ទុកជាអនុលេខាធិការបក្ស"។ លោក **នួន ជា** បានពន្យល់ថា គាត់ជា "អនុលេខាធិការទទួលបន្ទុកផ្នែកអប់រំ"[៦] និងមិនមានចំណែកចាត់ចែងការងារផ្នែកយោធាឡើយ ហើយថាវាជាការទទួលខុសត្រូវផ្តាច់មុខរបស់លេខាភូមិភាគនីមួយៗ ។ មេធាវី **ណេគ្វី** បានសួរផ្ទួញទៅកាន់ជនជាប់ចោទទាក់ទងនឹងមូលហេតុពាក់ព័ន្ធដូចម្តេច បានជា **ប៉ុល ពត** តាមដឹងមកថា បានចាត់ឲ្យជនជាប់ចោទទទួលបន្ទុកជាអ្នករៀបចំផ្លូវនៅតំបន់*កំពង់ត្រុំ* ខេត្ត*ព្រះវិហារ* ឆ្ពោះទៅកាន់*អង្គរវត្ត* កាលពីដំណើរទស្សនៈកិច្ចរបស់អតីតព្រះមហាវីរៈក្សត្រ ព្រះអង្គម្ចាស់ **នរោត្តម សីហនុ** កាលពីអំឡុងឆ្នាំ១៩៧៣ ។ មេធាវីតំណាងរដ្ឋប្បវេណី បាននិយាយសង្កត់ធ្ងន់ពីការទទួលបន្ទុកជាអ្នកមើលការខុសត្រូវលើភារៈបែបនោះថាជាការសំខាន់ខ្លាំង ដែលចាំបាច់ត្រូវតែមានវត្តមានលោក **នួន ជា** ជាអ្នកសង្កេតមើលប្រព័ន្ធការពារក្នុងតំបន់ចាត់តាំងដូចបានរៀបរាប់ខាងដើម ជាពិសេសតំបន់នោះ ត្រូវបានស្គាល់ថាជាតំបន់សង្គ្រាមក្តៅផងដែរ ។ លោក **នួន ជា** បានឆ្លើយបញ្ជាក់ដោយឥតរួញរាថា ពីព្រោះព្រះមហាក្សត្រជាបុគ្គលសំខាន់ណាស់ ដែលតម្រូវឲ្យមានការការពារឲ្យបានហ្មត់ចត់ រីឯក្នុងបេសកកម្មយាមកាម ចាំបាច់ណាស់ត្រូវមានកម្លាំងទ័ព ហើយខាងភូមិភាគមាននាទីរៀបចំប្រព័ន្ធការពារ ។ ពួកគេដាក់ពង្រាយកងទ័ពគេតាមដងផ្លូវ ដោយឡែករូបគាត់កន្លងមកមាននាទីកំណត់ត្រឹមការអប់រំ និងថា **ប៉ុល ពត** ជាប្រធានគណៈកម្មការយោធា ។

## *ក.៣. ការតស៊ូប្រដាប់អាវុធ*

លោក **នួន ជា** បានផ្តល់សក្ខីកម្មថា ក្នុងពេលធ្វើសន្និបាតបក្សលើកទី២ នាឆ្នាំ១៩៦២ បក្សបាន

សម្រេចរួមផ្សំនយោបាយ និងអាវុធផ្នែកពាយព្យទិស ប៉ុន្តែការតស៊ូអាវុធដែលខ្មែរក្រហមមានពេលនោះ គឺគ្រាន់តែមានដំបង និងកាំបិតសម្រាប់ការពារខ្លួនតែប៉ុណ្ណោះ ។ លោកតា **ទូ សាមុត** និង **ប៉ុល ពត**( *ក្រោយមកស្គាល់ថាជា សាឡុត ស*) បានដឹកនាំចលនាបដិវត្តន៍នោះ ។ ពួកគេបានស្នើសុំម្ហូបអាហារពីប្រជាជនក្នុងតំបន់ និងបរបាញ់សត្វព្រៃដើម្បីចិញ្ចឹមជីវិត ។ លោក **នួន ជា** បានទទូចថា នៅពេលនោះ គាត់មិនមានតួនាទីអ្វីជាក់លាក់ទេ តែគាត់បានអប់រំណែនាំស្តីពីសីលធម៌សង្គមដល់ប្រជាជន ដូចជា ឲ្យចេះរួបរួមសាមគ្គីគ្នា ចៀសវាងការផឹកស្រា និងមិនគួរប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ។

## *ក.៤. ដំណើរហេតុរបស់បក្សកុម្មុយនីស្តកម្ពុជាឆ្ពោះទៅកាន់វេទិកាអន្តរជាតិ*

ជនជាប់ចោទបានធ្វើដំណើរទៅខេត្ត **តាយនិញ** ប្រទេសវៀតណាមក្នុងអំឡុងឆ្នាំ១៩៦០ ដើម្បីធ្វើបទឧទ្ទេសនាមអំពីយុទ្ធសាស្ត្រ យុទ្ធវិធី និងមាគ៌ានយោបាយបក្សកុម្មុយនីស្តកម្ពុជា ។ គាត់ក៏បានប្រាប់ប្រទេសវៀតណាមអំពីឆន្ទៈនយោបាយ និងការតស៊ូអាវុធរបស់បក្សផងដែរ ។ បក្សកុម្មុយនីស្តវៀតណាម "ហាមផ្តាច់" មិនយល់ព្រមឲ្យបក្សកុម្មុយនីស្តកម្ពុជាមាននយោបាយតស៊ូអាវុធឡើយ ប៉ុន្តែលោក **នួន ជា** បានអះអាងតបថា បក្សកុម្មុយនីស្តកម្ពុជាមានជំនឿស៊ប់ និងមានម្ចាស់ការខ្លួនឯងគ្រប់គ្រាន់ដើម្បីដើរតាមមាគ៌ានយោបាយបក្ស។ លោក **នួន ជា** បានបន្តផ្តល់សក្ខីកម្មបន្តទៀតថា **ប៉ុល ពត** បានទៅធ្វើទស្សនៈកិច្ចនៅ ទីក្រុងប៉េកាំង នៅឆ្នាំ១៩៦៥ ដើម្បីជូនដំណឹងទៅថ្នាក់ដឹកនាំបក្សកុម្មុយនីស្តចិនអំពីមាគ៌ានយោបាយ និងយុទ្ធសាស្ត្របក្សកុម្មុយនីស្តកម្ពុជា ។ ពេលនោះបក្សកុម្មុយនីស្តកម្ពុជាមានតែចលនាតស៊ូតូចមួយតែប៉ុណ្ណោះ ដូច្នេះ ពួកគេត្រូវការបង្ហាញពីវត្តមានបក្សទៅកាន់វេទិកាអន្តរជាតិ ។ ដោយសារតែគោលបំណងនេះហើយ បានជា **ប៉ុល ពត** ចេញធ្វើទស្សនៈកិច្ចនៅប្រទេសចិនជាញឹកញាប់ ។

## *ក.៥. ទំនាក់ទំនងដ៏តឹងតែងជាមួយវៀតណាម*

លោក **នួន ជា** បានអះអាងថា នៅឆ្នាំ១៩៦៨ ប្រទេសចិនបានធ្វើជំនួយជាអាវុធដល់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែវៀតណាមបានលួចគ្រឿងសព្វាវុធផ្គត់ផ្គង់ទាំងនោះទុកជាកម្មសិទ្ធិខ្លួន និងប្រកែកមិនផ្តល់ឲ្យកម្ពុជា។ បើទោះជាលោក **នួន ជា** ផ្ទាល់ជឿជាក់ថា គ្រាប់រំសេវទាំងនោះ គឺជាសព្វាវុធស្របច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជាក្តីក៏គាត់ប្រកែកថា គាត់មិនបានណែនាំឲ្យ **សោ ភឹម** ទៅវាយដណ្តើមយកអាវុធពីឃ្លាំងដែលវៀតណាមលាក់ទុកនោះទេ ។

នៅខែមីនា ឆ្នាំ១៩៧៥ លោក **នួន ជា** បានជួបជាមួយនឹងថ្នាក់ដឹកនាំចលនាកុម្មុយនីស្តវៀតណាម ឈ្មោះលោក **ង្វៀន វ៉ាន់លិញ** ។ ជនជាប់ចោទបាននិយាយកោតសរសើរមេដឹកនាំរូបនេះ ថាជាបុគ្គលដែលអាចសន្ទនាគ្នាយល់ការបាន មិនដូចថ្នាក់ដឹកនាំចលនាកុម្មុយនីស្តផ្សេងទៀតរបស់វៀតណាមដែលមានចរិតឆេវឆាវ ជាពិសេសនៅពេលកម្ពុជាប្រាប់ថាមិនរណបវៀតណាម ។ គាត់បន្ថែមថា ទោះជាអាក្រក់ ឬល្អ ពួកគេមាននយោបាយតែមួយដើម្បីប្រយោជន៍ប្រទេសគេ ។ លោក **នួន ជា** ជឿជាក់ថា រូបគាត់ និងថ្នាក់ដឹកនាំវៀតណាម គ្រានោះ អាចជជែកដោះស្រាយគ្នាបានរវាងបញ្ហាបក្សកុម្មុយនីស្តកម្ពុជា និងទាហានវៀតណាម ។ ថ្វីបើមានកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់នូវភាពរង្គោះរង្គើដ៏វែងឆ្ងាយរវាងប្រទេសទាំងពីរនេះយ៉ាងណាក្តី ក៏ **ប៉ុល ពត** បានណែនាំមិនឲ្យចាត់ទុកវៀតណាមថា "ជាសត្រូវស្លាប់រស់"[៧] ឬសត្រូវស្ងួពូជដែរ តែចំពោះលោក **នួន ជា** វិញចាត់ទុកវៀតណាមថាជាសត្រូវឃោរឃៅជាងប្រទេសអាមេរិក ។ លោក **នួន ជា** បានចោទវៀតណាម

ថាមានចេតនាចង់លេបទឹកដីខ្មែរតាមរយៈបង្កើតរចនាសម្ព័ន្ធរដ្ឋបាលនៅប្រទេសកម្ពុជា ។ យើងឃើញថា មិនមានភាពពាក់ព័ន្ធអ្វីនឹងអង្គហេតុនីតិវិធីរបស់តុលាការឡើយ ចំពោះសេចក្តីអត្ថាធិប្បាយបន្ថែមរបស់លោក **នួន ជា** ត្រង់ចំណុចដែលគាត់បានបន្តបរិយាយពីការព្រួយបារម្ភជាទូទៅ ស្តីពីការលុកលុយចូលជាបន្តបន្ទាប់នៃប្រជាជនវៀតណាមក្នុងទឹកដីប្រទេសកម្ពុជា ក៏ដូចជាជោគវាសនានៃពលរដ្ឋកម្ពុជាជំនាន់ក្រោយៗទៀត ។

### *ក.៦. ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា*

នៅពេលដែលមានសំណួរសួរពីតួនាទីរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗទៀត លោក **នួន ជា** បាននិយាយថាពីឆ្នាំ១៩៧៣ ដល់១៩៧៥ គាត់ចាំមិនបានពីតួនាទីពិតប្រាកដរបស់ **សុន សេន** ក្នុងអង្គភាពយោធាទេ ។ ទោះជាយ៉ាងនេះក្តី ជនជាប់ចោទបានថ្លែងថា **សុន សេន** ធ្លាប់ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ហើយគាត់ក៏ជាមេដឹកនាំមួយរូបដែលបានទទួលបន្ទុករៀបចំការជម្លៀសចេញពីទីប្រជុំជននានា (ទីក្រុង) ។ លោក **នួន ជា** បាននិយាយថាលោក **អៀង សារី** ជាសហជនជាប់ចោទ បានទៅទីក្រុងប៉េកាំងនៅឆ្នាំ១៩៧៣ និង១៩៧៣ ហើយបានត្រឡប់មកកាន់ប្រទេសកម្ពុជាវិញតែម្តង ឬពីរដងតែប៉ុណ្ណោះ។ មានពេលមួយនោះ លោក **អៀង សារី** បានអមដំណើរអតីតព្រះមហាវីរៈក្សត្រ ព្រះអង្គម្ចាស់ **នរោត្តម សីហនុ** ទៅកាន់ខេត្តសៀមរាប ។ ទាក់ទងលើជនជាប់ចោទ **ខៀវ សំផន** វិញ លោក**នួន ជា** បានពន្យល់ពីពាក្យ “គណៈប្រធានរដ្ឋ គឺមានអំណាចខ្ពស់បំផុត” គឺចង់បង្ហាញថា ជាប្រធាននៃរដ្ឋដែលមានអំណាចគ្របដណ្តប់ទូទាំងប្រទេស ។ គាត់បានពន្យល់ថា នេះគឺជាអ្វីដែលប្រជាជនទូទៅយល់យ៉ាងដូច្នោះ ។ ថ្វីបើមានការលើកឡើងដូច្នេះមែន លោក **នួន ជា** មិនបានបន្តបរិយាយឲ្យល្អិតល្អន់អំពីបញ្ហានេះវែងឆ្ងាយទេ តែបានណែនាំភាគីម្ចាស់សំណួរ គឺសហព្រះរាជអាជ្ញាឲ្យសួរទៅលោក **ខៀវ សំផន** ដោយផ្ទាល់នូវព័ត៌មានបន្ថែម ពីព្រោះតែវាស្ថិតក្នុងការទទួលខុសត្រូវរបស់គាត់ ។

### *ក.៧. ការបញ្ឈប់មិនឲ្យប្រើរូបិយវត្ថុ (ក្រដាសប្រាក់)*

យោងតាមលោក **នួន ជា** បក្សកុម្មុយនីស្តកម្ពុជា មិនមានចេតនាបំបិទមិនឲ្យប្រើក្រដាសប្រាក់ទាំងស្រុងនោះទេ ខណៈដែលការចរាចរក្រដាសប្រាក់បានផ្អាកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានអះអាងថា ការទម្លាក់គ្រាប់បែកពីសំណាក់អាមេរិកកាំង បានបង្កឲ្យមានការខកខានមិនបានផលិតសម្ភារៈប្រើប្រាស់ទូទាំងប្រទេស ហើយស្បៀងក៏មានការខ្វះខាត នាំឲ្យការចរាចរក្រដាសប្រាក់ត្រូវបានបញ្ឈប់ ដូច្នេះ ប្រជាជនជួយគ្នាដោយការដោះដូរទំនិញ ក៏ដូចជាស្បៀងដែលនៅសេសសល់ខ្លះអាចចិញ្ចឹមគ្នាបានទើបការចាយវាយលុយកាក់ក៏លែងមានភាពចាំបាច់ ។ ក្នុងការឆ្លើយតបចំពោះបញ្ហានេះ បក្សកុម្មុយនីស្តកម្ពុជាបានសម្រេចចាត់តាំង (បង្កើត) *សមាគមស្រូវ* និង*សមាគមជួយសង្គ្រោះគ្នា* ។ លោក **នួន ជា** បានផ្តល់សក្ខីកម្មថា នៅតំបន់មួយចំនួន ការចរាចរក្រដាសប្រាក់នៅតែដំណើរការ ប៉ុន្តែដោយសារតែមូលហេតុថាមានពួកគិញអាមេរិកកាំង និងចារកម្មវៀតណាមបានប្រើប្រាស់ប្រាក់ដើម្បីទាក់ទាញកម្មាភិបាល ។ យោងតាមលោក **នួន ជា** ការផ្អាកការចរាចរក្រដាសប្រាក់មួយរយៈ អនុញ្ញាតឲ្យបក្សកុម្មុយនីស្តកម្ពុជាអាចគ្រប់គ្រងស្ថានភាពបាន និងអាចពង្រីកនូវតំបន់រំដោះកាន់តែបានច្រើនថែមទៀត ។

## *ក.៨. ការបង្កើតសហករណ៍*

លោក **នួន ជា** បានទទូចថា មិនមានការបង្ខំណាមួយឲ្យប្រជាជនចូលរួមបង្កើតសហករណ៍ទេ តែផលប្រយោជន៍នៃការមានសហករណ៍ គឺត្រូវបានពន្យល់ដល់ពួកគេថា៖ បើគ្មានសហករណ៍ទេ ពួកម្ចាស់ដីឃោរឃៅនឹងយកការប្រាក់ខ្ពស់កប់ពពកដល់អ្នកស្រុកដែលរកខ្ចីស្រូវ (*១០ថាំង យកប្រាំថាំង*) ឬបុល (ខ្ចី) លុយកាក់ក្តី ហើយពួកកងទ័ពវៀតណាមដែលបានដើរលុកលុយពេញទឹកដីប្រទេសកម្ពុជា នឹងប្រមូលទិញស្រូវអង្ករទាំងអស់ដែលប្រជាជនមាន ។ ដល់ចំណុចនេះ លោក **នួន ជា** បានអះអាងថា ថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតជាសហករណ៍ឡើង ក្នុងបំណងឲ្យប្រជាជនមានជង្រុករក្សាស្រូវសម្រាប់ចិញ្ចឹមជីវិតខ្លួនគេ ។ ទោះជាយ៉ាងនេះក្តី សហករណ៍មិនត្រូវបានរៀបចំនៅទូទាំងប្រទេសនៅឡើយទេ តែបានបន្តពង្រីកជាហូរហែពីតំបន់មួយទៅតំបន់មួយ ។ នៅពេលដែលគាត់ត្រូវបានសួរដោយមេធាវី **ណេគ្វី** ថាតើអាចនិយាយបានទេថា ប្រព័ន្ធសហករណ៍ ឬសមូហភាពដីធ្លី គឺជាធាតុសំខាន់បំផុតនៃបន្ទាត់នយោបាយ និងយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា លោក **នួន ជា** បានគូសបញ្ជាក់ថា “មិនមែនសហករណ៍ហ្នឹងវាសំខាន់បំផុតទេ វាគ្រាន់តែជារូបធម៌ (ជាទ្រង់ទ្រាយរូបសណ្ឋានដែលអាចផ្លាស់ប្តូរបាន) ។ សំខាន់បំផុត គឺមាគ៌ានយោបាយ យុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់បក្សកុម្មុយនីស្តកម្ពុជា” ។

## *ក.៩. សេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីភ្នំពេញ*

លោក **នួន ជា** បានបញ្ជាក់ថា មានកិច្ចប្រជុំពិសេសមួយក្នុងគណៈអចិន្ត្រៃយ៍បក្សនៅបណ្តោយដងស្ទឹង*ស្ទឹងជីនិត* កាលពីឆ្នាំ១៩៧៤ ។ កាលណោះ អ្នកចូលរួមប្រជុំមានដូចជា៖ លោក **ប៉ុល ពត** លោក **នួន ជា តាម៉ុក** លោក **សោ ភឹម** លោក **កុយ ធួន** លោក **សុន សេន** និងតំណាងមកពីខាងភូមិភាគមួយចំនួន ក៏ដូចជាបុគ្គលផ្សេងទៀតដែលលោក **នួន ជា** មិនបានចាំអស់ ។ ប្រជុំមួយនេះហើយ ដែលធ្វើឲ្យគណៈអចិន្ត្រៃយ៍បក្សចេញសេចក្តីសម្រេចជម្លៀសប្រជាជនពីភ្នំពេញ និងរំដោះបានទូទាំងប្រទេស ។ លោក **នួន ជា** បានទទួលស្គាល់បន្ថែមទៀតថា គាត់មានវត្តមាននៅភ្នំពេញពីខែមករា ដល់ខែមេសា ឆ្នាំ១៩៧៥ ។

លោក **នួន ជា** បានបរិយាយថា ការជម្លៀសបណ្តោះអាសន្នពីទីក្រុងភ្នំពេញ ជាការឆ្លើយតបនឹងសេចក្តីប្រកាសធ្វើដោយសន្និបាតអាមេរិក ដែលថ្លែងថានឹងឈប់ផ្តល់ជំនួយហិរញ្ញវត្ថុដល់ការទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជា ។ គាត់បានបញ្ជាក់ជាថ្មីម្តងទៀតថា ការជម្លៀសនៅភ្នំពេញ គឺដើម្បីជួយសង្គ្រោះអាយុជីវិតប្រជាជនដែលកំពុងរស់នៅក្នុងទីប្រជុំជននេះឲ្យផុតពីការខ្វះខាតស្បៀងអាហារ ។ គាត់បានបញ្ជាក់ថា ប្រជាជនទាំងនោះ បានដឹងខ្លួនជាស្រេចហើយថាពួកគេនឹងត្រូវតែចាកចេញ ហើយអ្នកដែលមានកម្លាំងពលំបានជួយជ្រោមជ្រែង លីសែងអ្នកជម្ងឺ ឬអ្នកដែលទន់ខ្សោយជាងខ្លួនក្នុងពេលធ្វើដំណើរដោយខ្លួនគេ ។ អ្នកជម្លៀសទាំងនោះ ត្រូវបានបញ្ជូនឲ្យទៅកាន់សហករណ៍មួយចំនួន ដើម្បីនាំគ្នាធ្វើស្រែចម្ការចិញ្ចឹមជីវិត ។ លោក **នួន ជា** ក៏បានតវ៉ាផងដែរថាគ្រានោះ ខ្មែរក្រហមមិនជឿថាអាមេរិកព្រមចុះចាញ់ទេ ហើយបើអាមេរិកវ៉ៃពិតមែន កងទ័ពវៀតណាម ឬវៀតកុងក៏មិននៅស្ងៀមដែរ ពីព្រោះពួកគេបានលបលួចចូលក្នុងភ្នំពេញខ្លះៗ ហើយជាប្រការដែលអាចបង្កឲ្យមានការស្លាប់មនុស្សកាន់តែច្រើន ។ ដូច្នេះ អាចមានទាំងសង្គ្រាមក្នុងទីក្រុងភ្នំពេញ បន្ថែមលើការខ្វះខាតស្បៀងដែលមានស្រាប់ហើយនោះ ។ លើសពីនេះទៀត លោក **នួន ជា** បាននិយាយថា ស្ថានភាពតក់ក្រហល់ដូចបានលើកឡើងនេះ បានមិនបានធ្វើឲ្យខ្មែរក្រហមគិតគូរវែងឆ្ងាយពីកិច្ចប្រតិបត្តិការយ៉ាងណានោះទេ ពោលគឺត្រូវចេញទាំងអស់ ទាំងអ្នកជម្ងឺតាមបណ្តាមន្ទីរពេទ្យមួយចំនួនក្តី ។

### *ក.១០. ប្រជាជនមូលដ្ឋាន ប្រជាជនថ្មី និងសមាសភាពមិនល្អ*

ឆ្លើយតបទៅនឹងសំណួរមួយចំនួនពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ស៊ិន-ស៊ីវន** ស្តីពីសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា លោក **នួន ជា** បានបញ្ជាក់ថា នៅពេលដែលគាត់នៅជាសមាជិកនៃអ្នកតស៊ូក្រោមការគ្រប់គ្រងរបស់ "បក្សប្រជាជនបដិវត្តន៍កម្ពុជា" (*ជាឈ្មោះដែលមានមុនបង្កើតបក្សកុម្មុយនីស្តកម្ពុជា*) ពាក្យថា "សត្រូវ" គឺសំដៅទៅលើជនបរទេសទាំងឡាយដែលមានចេតនាចង់លេបយកទឹកដីប្រទេសកម្ពុជា បក្ខពួករបស់ចក្រពត្តិ ពួកសក្តិភូមិដែលសង្កត់សង្កិនប្រជាជន និងជនក្បត់របស់ប្រទេសជាតិ ។ នៅពេលសួរអំពីតើក្រុមប្រជាជនប្រភេទណា ជាប្រជាជនរបស់បក្សកុម្មុយនីស្តកម្ពុជា លោក **នួន ជា** បានរៀបរាប់ថា គឺគ្រប់គ្នាដែលស្ថិតក្នុង "វណ្ណៈស្អាតស្អំ" ។ គាត់ក៏បានពន្យល់ពីខ្លឹមសារ ដែលគាត់ចង់សំដៅនៅពេលនិយាយពីពាក្យ "វណ្ណៈស្អាតស្អំ" គឺថាជាគំនិតយកតាមទ្រឹស្តី ពីព្រោះនៅក្នុងភាពជាក់ស្តែងមាន "សមាសភាពមិនល្អ" សូម្បីតែនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ។ គាត់បានទទួលស្គាល់ថា មិនមែនរាល់បក្ខជន ឬសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាទាំងអស់សុទ្ធតែល្អនោះទេ ប៉ុន្តែគាត់បានបញ្ជាក់ថា ភាគច្រើននៃពួកគេ គឺជាមនុស្សល្អ ។

ជនជាប់ចោទបានពន្យល់ពីខ្លឹមសារនៃ "ប្រជាជនថ្មី" ថាជាអ្នកដែលត្រូវបានជម្លៀស រីឯ "ប្រជាជនមូលដ្ឋាន" វិញ គឺជាប្រជាជនម្ចាស់ភូមិឋាន ឬជាអ្នកស្រែចម្ការ ប៉ុន្តែគាត់បានគូសបញ្ជាក់ថា មិនមានការរើសអើងណាមួយទេរវាង "ប្រជាជនថ្មី" និង"ប្រជាជនមូលដ្ឋាន" ។ គាត់បានបន្តអះអាងថា គណៈមជ្ឈិមបក្សបានបង្រៀនប្រជាជនមិនឲ្យមានការរើសអើងរវាងអ្នកចាស់ និងអ្នកថ្មី ដូចជាថា៖ ពួកយើងសុទ្ធតែជាខ្មែរ គួរតែចែះចែករំលែកទុក្ខធុរៈគ្នា ជួយគ្នាទៅវិញទៅមកនូវអ្វីដែលមាន រួមមានទាំងម្ហូបអាហារជាដើម ។ លោក **នួន ជា** បានបន្ថែមក្នុងសក្ខីកម្មរបស់គាត់ថា "ប្រជាជនល្អ" គឺជាអ្នកដែលមានសីលធម៌ បង្ហាញពីការរួបរួម កម្លាំងសាមគ្គីជាមួយខ្មែរគ្នាឯង និងមិនមែនកាចសាហាវយង់ឃ្នងឡើយ ។ លោក **នួន ជា** បានបន្ថែមថា មានតែ "សមាសភាពមិនល្អ" តែប៉ុណ្ណោះ ដែលប្រព្រឹត្តការរើសអើង ប្រឆាំងនឹង "ប្រជាជនថ្មី" ។

## ខ. សេចក្តីសន្និដ្ឋាននៃការផ្តល់សក្ខីកម្មរបស់អ្នកស្រី ប្រាក់ យុត

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី កញ្ញា **ហ្វីលីពីន ស៊ុតហ្ស៍** និងមេធាវីប្រឹក្សាក្តីអន្តរជាតិរបស់លោក **នួន ជា** គឺលោក **ម៉ែខល ផេស្តមិន** បានសួរបញ្ចប់សក្ខីកម្មលើអ្នកស្រី **ប្រាក់ យុត** បន្ទាប់ពីមេធាវីការពារក្តីលោក **អៀង សារី** និងលោក **ខៀវ សំផន** បដិសេធមិនសួរសំណួរអ្វីទាំងអស់ដល់សាក្សីនេះ ។

អ្នកស្រី **ប្រាក់ យុត** បានគូសបញ្ជាក់ម្តងហើយម្តងទៀតថា អ្នកស្រីបានប្រាប់តុលាការតែការពិត និងមិនមានការភ័យខ្លាចនឹងនិយាយឡើយនូវអ្វីដែលអ្នកស្រីបានដឹង ។

### *ខ.១. តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

អ្នកស្រី **ប្រាក់ យុត** បានផ្តល់សក្ខីកម្មថា អ្នកស្រីជាសមាជិកទី៤នៃតំបន់លេខ៤១ ។ អ្នកស្រីបានទទួលបន្ទុកផ្នែកសន្តិសុខនៅស្រុក*កំពង់សៀម* និងមាននាទីអប់រំណែនាំដល់ប្រជាជនក្នុងមូលដ្ឋាន ។ មេធាវី **ស៊ុតហ្ស៍** បានសួរនូវសំណួរមួយចំនួនអំពីមណ្ឌលសន្តិសុខក្នុងស្រុកអ្នកស្រីកាន់កាប់ មានទីតាំងក្នុងវត្ត*អង្គញដី* ។ អ្នកស្រី **ប្រាក់ យុត** និយាយថា មិនមានអ្នកណាម្នាក់ទទួលបន្ទុកក្នុងតំបន់នេះទេ ព្រោះតែពេលនោះ មិនទាន់មានការរៀបចំពេញលេញនៅឡើយ ។ សាក្សីរូបនេះបានបន្តចង្អុលបង្ហាញថា នៅស្រុក*កំពង់*

*សៀម* មិនមានទីសម្លាប់មនុស្សទេ ។ នៅពេលដែលបានសួរអំពីថាតើ អ្នកស្រីបានឮអំពីរឿងរ៉ាវខ្លះៗនៅ*ភ្នំប្រុសភ្នំស្រី* សាក្សីបាននិយាយថា អ្នកស្រីបានឃើញភ្នំនេះ តែមិនដែលដឹងថាមានការសម្លាប់ណាមួយបានកើតឡើងនៅទីនោះឡើយ ។ អ្នកស្រីបន្ថែមថា គាត់មិនបានទៅមើលកន្លែងនេះញឹកញាប់ទេ និងបានធ្វើការតែនៅក្នុងការិយាល័យស្រុក ។ លើសពីនេះទៀត សាក្សីបានបញ្ជាក់ថា នៅពេលដែលអ្នកស្រី ត្រូវបានគេបញ្ជូនទៅតំបន់លេខ៣៥មក អ្នកស្រីត្រូវបានចាត់ឲ្យទទួលបន្ទុកផ្នែកកិច្ចការនារី ។ សាក្សីបាន ផ្តល់សក្ខីកម្មបន្តទៀតថា អ្នកស្រីមិនធ្លាប់ក្លាយជាសមាជិកនៃគណៈភូមិភាគកណ្តាលទេ បើទោះជាខ្លួនបានចូលរួមប្រជុំជាមួយគណៈភូមិភាគក្តី ។

ចំណុចគួរកត់សម្គាល់ អ្នកស្រី**ប្រាក់ យុត** បានផ្តល់សក្ខីកម្មថា ចំពោះបុគ្គលទាំងឡាយណា ដែលមិនអាចធ្វើ “ការអប់រំកែប្រែ” បាន ឬបុគ្គលណាដែលមានអត្តចរិត “មិនសមរម្យ” នឹងត្រូវបានគេបញ្ជូនទៅការិយាល័យស្រុក ដើម្បីធ្វើការ “អប់រំកែប្រែជាថ្មីម្តងទៀត” ។ អ្នកស្រីបានទទួលស្គាល់ថា អ្នកស្រីបានធ្វើការសម្រេចនេះដោយខ្លួនឯងផ្ទាល់ បើទោះណាជាគ្មានបញ្ជាពីថ្នាក់លើក្តី ។

### *ខ.២. ការដឹងឮពីភាពប្រហាក់ប្រហែលទៅលើ តា អាន និង អ៊ឹម ចែម (តាមដឹងមកថា ជាបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤)*

សាក្សី**ប្រាក់ យុត** បានបញ្ជាក់ថា អ្នកស្រី ស្គាល់ **តា អាន** និងអ្នកស្រី **អ៊ឹម ចែម** ។ អ្នកស្រីបាន រម្លឹកឡើងវិញថា អ្នកស្រី និង **តា អាន** ជាសមាជិកលេខានៃគណៈតំបន់លេខ៣៥ ។ ក្រោយមក **តា អាន** បានក្លាយជាប្រធានតំបន់លេខ៤១ ។ អ្នកស្រីមិនបានដឹងទេ ថាតើ**តា អាន** មានទំនាក់ទំនងជាមួយនឹងភូមិភាគកណ្តាល ។ សាក្សីក៏បានបកស្រាយផងដែរ ថាអ្នកស្រីមិនបានដឹងទេ ថាតើ **តា អាន** កំពុងតែនៅរស់រានមានជីវិតដល់សព្វថ្ងៃ ព្រោះអ្នកស្រីមិនដែលបានជួបគាត់សោះបន្ទាប់ពីបែកបាក់គ្នាក្នុងអំឡុងពេល “យួន” ចូលស្រុក *(យួន គឺសំដៅទៅលើជនជាតិវៀតណាម*) ។ អ្នកស្រី **ប្រាក់ យុត** បានបញ្ជាក់ថា នៅពេលដែលអ្នកស្រីទទួលបន្ទុកលើកិច្ចការនារីថ្នាក់តំបន់លេខ៣៥ អ្នកស្រីបានឃើញអ្នកស្រី **អ៊ឹម ចែម** ក្នុងពេលប្រជុំ ហើយសាក្សីដឹងថា អ្នកស្រី **អ៊ឹម ចែម** ជាអ្នកដែលបានទទួលបន្ទុកផ្នែកកិច្ចការនារីក្នុងតំបន់១៣ ។ ទោះជាយ៉ាងនេះក្តី ពួកគាត់ទាំងពីរមិនបានទាក់ទងគ្នាអំពីការងារដែលបានធ្វើយ៉ាងណានោះឡើយ ។

## គ. សក្ខីកម្មរបស់សាក្សី ឆាំង យុ

អំឡុងពេលសវនាការកាលពីសប្តាហ៍មុន ក្រុមមេធាវីការពារក្តីបានស្នើសុំកោះហៅលោក **ឆាំង យុ** នាយករបស់ *ឌី.ស៊ី.ខេម* ឲ្យធ្វើសម្បថដើម្បីចូលខ្លួនមកស្រាយបំភ្លឺស្តីពីវិធីសាស្ត្រនៃការទទួលបានឯកសារ ការកំណត់យថាភាព ការរៀបចំចាត់ថែង និងការចុះឈ្មោះក្នុងបញ្ជីលេខរៀងលើឯកសារពីរបបខ្មែរក្រហមដែល អ.វ.ត.ក បានទទួលយកដាក់ក្នុងឯកសារសំណុំរឿង ។ សប្តាហ៍នេះ អង្គជំនុំជម្រះបានកោះហៅលោក **ឆាំង យុ** ចូលផ្តល់សក្ខីកម្ម ហើយភាគីមានឱកាសក្នុងការសួរដេញដោលគាត់ស្តីពីគោលនយោបាយរបស់ *ឌី.ស៊ី.ខេម* នីតិវិធីរៀបចំទទួល និងទុកដាក់ឯកសារ បូករួមទាំងបំភ្លឺពីការអនុវត្តជាក់ស្តែងដូចម្តេចខ្លះ ។ ក្នុងអំឡុងពេលសួរដេញដោល សាក្សីបានបង្ហាញនូវឯកសារមួយចំនួនដែលបានមកពីមជ្ឈមណ្ឌលរបស់លោក ដើម្បីពន្យល់ពីប្រភពពាក់ព័ន្ធផ្សេងៗដល់អង្គជំនុំជម្រះ។

### *គ.១. គោលដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ឌី.ស៊ី.ខេម)និងការបង្កើតស្ថាប័ននេះ*

លោក **ឆាំង យុ** គឺជាអគ្គនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬ *ឌី.ស៊ី.ខេម* បានផ្តល់សក្ខីកម្មថា អង្គការរបស់លោកត្រូវបានបង្កើតឡើងកាលពីឆ្នាំ១៩៩៥ ក្នុងបំណងប្រមូលផ្តុំឯកសារក្នុងរបបខ្មែរក្រហម និង ដើម្បីលើកទឹកចិត្តឲ្យមានការផ្សះផ្សានៅប្រទេសកម្ពុជា ។ *ឌី.ស៊ី.ខេម* មានគោលបំណងបីសំខាន់ៗគឺៈ (ក) តស៊ូមតិដើម្បីតុលាការមានឯករាជ្យក្នុងការស្វែងរកការពិត (ខ) ធ្វើការផ្តល់នូវព័ត៌មានត្រឹមត្រូវផ្នែកប្រវត្តិ-សាស្ត្រដល់យុវជនកម្ពុជាជំនាន់ក្រោយ និង (គ) បង្កើតនូវមជ្ឈមណ្ឌលឯកសារដើម្បីជាប្រយោជន៍ដល់ការ ស្រាវជ្រាវ ។

### *គ.២. ដំណើរការទទួលបានឯកសារ*

នៅពេលដែលសួរទាក់ទងនឹងគោលដៅរបស់អង្គការក្នុងការប្រមែប្រមូលឯកសារ សាក្សីបានផ្តល់នូវ ចម្លើយស្រពិចស្រពិលមួយចំនួន ។ គាត់បានរាយរាប់នូវបញ្ជីប្រភពនៃមធ្យោបាយដែលបានប្រើប្រាស់ ការ ប្រមូលឯកសារបានពីចំណុចខុសៗគ្នាក្នុងពេលតែមួយជាដើម ។ គាត់បានពន្យល់ថា *ឌី.ស៊ី.ខេម* បានចេញ សេចក្តីប្រកាសជាសាធារណៈកាលពីប៉ុន្មានឆ្នាំមុននេះ ដើម្បីស្នើសុំទាំងបុគ្គលឯកជន ទាំងស្ថាប័ន និងបណ្តា ប្រទេសមួយចំនួនឲ្យប្រគល់នូវរាល់ឯកសារពាក់ព័ន្ធក្នុងរបបខ្មែរក្រហមដល់អង្គការលោក ដើម្បីចងក្រងទុក ដាក់ ។ តាមដឹងមកថា ឆ្លើយតបនឹងការអំពាវនាវនេះ ឯកសារប្រវត្តិសាស្ត្រមួយចំនួនត្រូវបានប្រគល់ឯកសារ ដល់អង្គការលោក ។ ផ្នែកខ្លះនៃកិច្ចការប្រមែប្រមូលរបស់អង្គការនេះ ត្រូវបានប្រគល់ឲ្យដោយបុគ្គលមួយ ចំនួននៅជុំវិញប្រទេសកម្ពុជាផងដែរ ក្រោមហេតុផលផ្សេងៗគ្នា ។ ជាឧទាហរណ៍ សាក្សីបានផ្តល់សក្ខីកម្មថា នៅពេលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅកាត់ថា **អ.វ.ត.ក** ត្រូវបានបង្កើតហើយ មនុស្សម្នា មួយចំនួនដែលមានបំណងចង់ចែកចាយព័ត៌មានជាមួយ **អ.វ.ត.ក** បានយកឯកសារដែលពួកគេមានមកឲ្យ អង្គការគាត់ ជំនួសឲ្យការធ្វើដោយផ្ទាល់ទៅតុលាការ ។ មានបុគ្គលឯកជនផ្សេងៗទៀតបានចែករំលែកព័ត៌ មានជាមួយអង្គការលោក នៅពេលដែលមានតំណាងពីអង្គការធ្វើដំណើរចុះតាមបណ្តាខេត្តនានា ក៏ដូចជា តាមបណ្តាប្រទេសមួយចំនួនដើម្បីប្រមូលឯកសារ ។

លោក **ឆាំង យុ** បានរៀបរាប់អំពីប្រភពឯកសារខ្លះៗទទួលបានពីរាជរដ្ឋាភិបាលផងដែរ រួមមានដូច ជាៈ ពីក្រសួងមហាផ្ទៃ បណ្ណសារដ្ឋានជាតិ សារមន្ទីរទួលស្លែង ការិយាល័យអប់រំមជ្ឈិម (ក្រសួងវប្បធម៌ និង ព័ត៌មាន) និងបានពីក្រសួងអប់រំយុវជន និងកីឡា ។ នៅក្នុងចំណុចលេខ ៥ (គ) ផ្នែកខាងក្រោមនៃរបាយ ការណ៍នេះ នឹងផ្តល់ព័ត៌មានលម្អិតអំពីប្រភេទឯកសារ ដែលបានទទួលពីប្រភពដែលទើបតែរៀបរាប់ពេល នេះ។

យោងតាមសាក្សីបានឲ្យដឹងថា *ឌី. ស៊ី. ខេម* មានឯកសារជាសរុបប្រមាណជា១លាន "ទំព័រ" ដែល ចំនួននេះត្រូវបានពន្យល់ថាជា ១លាន "ឯកសារ" បើផ្អែកតាមការពន្យល់ពីអង្គការនេះ។[៨] ថ្វីបើភាគច្រើននៃ ឯកសារត្រូវបានអះអាងពីសាក្សីថា បានត្រួតពិនិត្យគ្រប់សន្លឹកទាំងអស់ ដើម្បីធ្វើសេចក្តីសម្រេចថាឯកសារ ទាំងនេះពិត ឬមិនពិតថាបានស្ថិតនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទាក់ទងទៅនឹងបញ្ហាគោល នយោបាយវិញ បន្ទាប់ពីការកំណត់អត្តសញ្ញាណដំបូងទីមក សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានផ្ញើឯកសារ ទាំងនោះទៅឲ្យនាយករងរបស់គាត់ គឺលោក **វ៉ានថាន់ ពៅដារា** (*ជាបុគ្គលដែល* ***អ.វ.ត.ក*** *កោះហៅឲ្យមក*

*ផ្តល់សក្ខីកម្មស្តីពីនីតិវិធីទាំងឡាយរបស់ ឌី ស៊ី ខេម*) ដើម្បីឲ្យស្ថាប័នលោក ធ្វើប្រតិបត្តិការរក្សាទុកដាក់ដោយថតចម្លង និងចងក្រងទុក ។ ក្រោយពីនោះមក លោក **វ៉ាន់ថាន់ ពៅដារា** បានចាត់បុគ្គលិកជំនាញក្រោមការគ្រប់គ្រងរបស់គាត់ឲ្យអាន ធ្វើការសង្ខេប បកប្រែ កំណត់យថាភាព ចម្លងទុកក្នុងមីក្រូហ្វីល និងចុះបញ្ជីឯកសារនីមួយៗទៅក្នុងបញ្ជីទិន្នន័យរបស់អង្គការនេះ ។ បន្ទាប់មកទៀត ឯកសារត្រូវបានរក្សាទុកយ៉ាងហ្មត់ចត់ ដោយមានតែលោក និងអនុប្រធានរូបនេះតែប៉ុណ្ណោះដែលអាចរកមើលបាន ។

### *គ.៣. យថាភាពនៃឯកសារ*

សហព្រះរាជអាជ្ញាជាតិ លោក **ច័ន្ទ តារាស្មី** បានសុំឲ្យសាក្សីធ្វើការបញ្ជាក់ពីអត្ថន័យដែលសាក្សីចង់សំដៅនៅពេលនិយាយពី "ឯកសារដើម" ។ សាក្សីបានពន្យល់ថា "...ឯកសារដែលគ្មានវត្តមានឯកសារដើមនៅក្នុងកម្ពុជា ក៏យើងចាត់ទុកថាជាឯកសារដើមដែរ សម្រាប់ឯកសារទាំងឡាយណាដែលមិនទាន់" ។[៩] មិនមានភាពច្បាស់លាស់នៅឡើយទេ ថាតើមានឯកសារប៉ុន្មានក្នុងចំណោម ១លានឯកសារ ដែល*ឌី.ស៊ី.ខេម* មានជាឯកសារដើមពិតប្រាកដដូចម្តេច ហើយតើមានឯកសារថតចម្លងប៉ុន្មានដែលត្រូវស្ថិតក្រោមការពន្យល់ពីលោក **ឆាំង យុ** ថាជា "ឯកសារដើម" ។ សាក្សីបានគូសបញ្ជាក់ថា រាល់ឯកសារដែលអង្គការលោកផ្ញើទៅ **អ.វ.ត.ក** គឺសុទ្ធតែបានចង្អុលបង្ហាញច្បាស់ ថាឯកសារនោះជាឯកសារដែលបានថតចម្លងចេញ*(ស្កេន និងថតចម្លង*) ពីឯកសារដើម ឬចម្លងចេញពីឯកសារថតចម្លងបន្ត ។[១០] នៅពេលសួរថា តើ*ឌី.ស៊ី.ខេម* ធ្វើការសម្រេចលើយថាភាពនៃឯកសារនីមួយៗដូចម្តេច ហើយធ្វើម៉េចដឹងថាឯកសារនោះមិនមែនជាការច្នៃប្រឌិត លោក **ឆាំង យុ** បានថ្លែងថា ការវិភាគរបស់គាត់ គឺផ្អែកទៅលើពណ៌ក្រដាស ការចុះថ្ងៃខែ អ្នកនិពន្ធ ខ្លឹមសារ និងរបៀបប្រើប្រាស់ភាសានៅក្នុងឯកសារ ។ លោក **ឆាំង យុ** បានចង្អុលបង្ហាញបន្តទៀតថា ក្រុមការងារលោកមិនគ្រាន់តែពិនិត្យពិច័យលើឯកសារតែម្យ៉ាងនោះទេ តែថែមទាំងត្រូវអាននូវសន្ទានស័ព្ទ (*ការតភ្ជាប់*) ជាមួយនឹងបរិបទពាក់ព័ន្ធរបស់វាផងដែរ ។ គាត់បានទទួលស្គាល់ថា *ឌី.ស៊ី.ខេម* មិនបានជួលអ្នកវិទ្យាសាស្ត្រដែលមានចំណេះដឹងខាងផ្នែកកោសល្យវិច័យ "ឆ្អឹង" នៃឯកសារដើម្បីធ្វើការបញ្ជាក់ពីយថាភាពឡើយ ។

### *គ.៤. ការផ្ទៀងផ្ទាត់លើការថតចម្លង*

មេធាវីប្រឹក្សាក្តីអន្តរជាតិឲ្យលោក **ខៀវ សំផន** គឺលោក **អាទូរ វែកគែន** បានទាមទារឲ្យសាក្សីប្រាប់ពីទីកន្លែងរក្សាទុកឯកសារជាក់លាក់ក្នុងបណ្ណសារដ្ឋានរបស់*ឌី.ស៊ី.ខេម* ។ សាក្សី បានតវ៉ាថាគាត់មានការស្ទាក់ស្ទើរក្នុងការបកស្រាយជាសាធារណៈអំពីទីតាំងរក្សាទុកឯកសារប្រភេទក្រដាស ពីព្រោះ ទាក់ទងនឹងបញ្ហាសន្តិសុខ ។ ប្រធានតុលាការបានប្រាប់ដល់សាក្សី និងភាគីថា ដើម្បីធានានូវសុវត្ថិភាព និងសន្តិសុខនៃឯកសារទាំងនោះ វាមិនមានភាពចាំបាច់ទេដល់សាធារណជនក្នុងការដឹងថា តើឯកសារទុកនៅឯណាពិតប្រាកដ ។ អង្គចៅក្រម ក៏បានបដិសេធនូវការស្នើរបស់មេធាវីការពារក្តីលោក **នួន ជា** ដែលស្នើសុំធ្វើសវនាការអសាធារណៈ ដើម្បីអាចឲ្យសាក្សី **ឆាំង យុ** ប្រាប់ភាគីបានថាតើសំណុំឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ នោះកំពុងរក្សាទុកនៅទីណាពិតប្រាកដ ។ ក្រោយមក ប្រធានតុលាការក៏បានសួរទៅកាន់សាក្សី **ឆាំង យុ** ថាតើឯកសារទាំងឡាយបានថតចម្លងពីច្បាប់ដើម ហើយដែលឯកសារដែលបានថតចម្លងនោះ ត្រូវបានផ្ទៀងផ្ទាត់

ជាមួយឯកសារដើមដែរឬទេ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានធានាជូនអង្គជំនុំជម្រះថា *ឌី.ស៊ី.ខេម* នឹងអាចជួយបាននៅពេលណាដែលអង្គជំនុំជម្រះចង់ធ្វើការផ្ទៀងផ្ទាត់ចម្លងទាំងនេះជាមួយឯកសារដើម ។

មេធាវី **វ៉េកតែន** បានចាប់ផ្តើមសួរទៅកាន់សាក្សីថា ប្រសិនបើមានភាគីណាមួយនៃសំណុំរឿងនេះដាក់ការស្នើទៅ*ឌី.ស៊ី.ខេម* ដើម្បីសុំមើលឯកសារច្បាប់ដើម ដើម្បីឲ្យភាគីអាចសួររកដើមចមនៃឯកសារទាំងនោះដែរឬទេ ។ សំណួរនេះ ហាក់ដូចជាមិនបានធ្វើឲ្យសាក្សីយល់ច្បាស់ទេ ដោយគាត់បានកាត់យល់ខ្លួនគាត់ដូច្នេះថា តើមានភាគីណាបានស្នើ *ឌី.ស៊ី.ខេម* ឲ្យផ្ទៀងផ្ទាត់ឯកសារដែរឬទេ បើទោះណាជាមេធាវី **វ៉េកតែន** បានសួរច្រំដែលនូវសំណួរដូចនេះក៏ដោយ ។ យោងតាមសាក្សី **ឆាំង យុ** ទាំងភាគីសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត “ពុំដែលបានស្នើសុំមើលឯកសារផ្ទៀងផ្ទាត់ទេ ប៉ុន្តែបានស្នើសុំធ្វើការស្កេន (ចម្លង) ដោយខ្លួនឯងចេញពីឯកសារដើម...” ។[១១] ទោះជាយ៉ាងនេះក្តី គាត់បានពន្យល់នៅក្នុងសក្ខីកម្មរបស់គាត់ក្រោយមកទៀតថា កាស្នើរបស់សហព្រះរាជអាជ្ញាបានរាប់បញ្ចូលទាំងការសុំឲ្យ *ឌី.ស៊ី.ខេម* ធ្វើការបញ្ជាក់ពីយថាភាពនៃឯកសារផងដែរ ។ នៅឆ្នាំ២០០៧ សាក្សីបានផ្តល់ការបញ្ជាក់ពីយថាភាពនៃឯកសារចំនួន ៦ ទៅ ៧ទំព័រ ដែលបានកំណត់ទាំងដំណើរការនៃការស្រាវជ្រាវ និងដំណើរការផ្តល់យថាភាពនៃឯកសារ ។ សាក្សីលម្អិតថែមទៀតថា រាល់សំណើរបស់សហព្រះរាជអាជ្ញានីមួយៗ *ឌី.ស៊ី.ខេម* តែងតែបញ្ជាក់នៅក្នុងបញ្ជីដែលផ្តល់ឯកសារ ថាតើវាជាប្រភេទឯកសារដើម ឬជាប្រភេទឯកសារថតចម្លង ។ សាក្សីបាននិយាយថា ព័ត៌មានដូចគ្នានេះត្រូវបានចុះទៅក្នុងកំណត់ត្រារបស់*ឌី.ស៊ី.ខេម* ។

### *គ.៥. ខ្សែចង្វាក់ចម្បងនៃការប្រមូលផ្តុំ*

ពាក់ព័ន្ធនឹងខ្សែចង្វាក់នៃការរក្សាទុកឯកសារ លោក **ឆាំង យុ** បានពិភាក្សាអំពីប្រភពចម្បងនៃឯកសារដែល*ឌី.ស៊ី.ខេម* កំពុងកាន់កាប់ និងកាលៈទេសៈមួយចំនួនដែលអង្គការមួយនេះបានទទួលឯកសារពីមជ្ឈដ្ឋានខាងក្នុង និងខាងក្រៅ ។

**ឯកសារដែលទទួលបានពីក្រសួងមហាផ្ទៃ:** យោងតាម សាក្សី **ឆាំង យុ** បណ្តុំឯកសារដែល*ឌី.ស៊ី.ខេម* ទទួលបានពីក្រសួងមហាផ្ទៃ រួមបញ្ចូលទាំងឯកសារជាខ្សែវីដេអូរ និងឯកសារជាប្រភេទក្រដាស ។ ឯកសារដើមដែលទទួលបានពីទីនោះសរុបប្រមាណជា១ពាន់ច្បាប់ រាប់បញ្ចូលទាំងរូបថត ប្រវត្តិរូបរបស់បុគ្គលផ្សេងៗ ការឆ្លើយឆ្លងព័ត៌មាន និងឯកសារជាចម្លើយសារភាព ។ ចំពោះប្រវត្តិរូបបុគ្គលវិញ ភាគច្រើនជាប្រវត្តិរូបរបស់អ្នកជាប់ឃុំឃាំង តែខ្លះទៀតក៏មានប្រវត្តិរូបរបស់កម្មាភិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ។ ប្រភេទឯកសារទាំងនេះត្រូវបានរកឃើញអំឡុងឆ្នាំ១៩៨២ ឬ១៩៨៣ នៅក្នុងផ្ទះមួយមុំផ្សារ *សេលីប* និងនៅតាមបណ្តោយផ្លូវនៃស្ថានទូតអាមេរិកកាំងនាពេលបច្ចុប្បន្ននេះ ។ ឯកសារ ត្រូវបានរកឃើញដោយក្រុមអ្នកស្រាវជ្រាវមួយ ដែលក្រោយមកបានក្លាយជាបុគ្គលិករបស់ក្រសួងមហាផ្ទៃ។[១២] ឯកសារទាំងនេះ បានធ្លាក់ក្នុងដៃ*ឌី.ស៊ី.ខេម* កាលពីឆ្នាំ១៩៩៩ ។

**ឯកសារបានពីបណ្ណសារដ្ឋានជាតិ និងបណ្ណសារដ្ឋាននៅទួលស្លែង:** *ឌី.ស៊ី.ខេម* មិនបានកាន់កាប់ឯកសារដើមដែលមានប្រភពចេញពីបណ្ណសារដ្ឋានជាតិ និងបណ្ណសារដ្ឋាននៅទួលស្លែងទេ ប៉ុន្តែបានថតចម្លងយកចេញពីស្ថាប័នជាតិទាំងពីរនេះ ។ ដើម្បីធ្វើការបញ្ជាក់ពីយថាភាពនៃឯកសារទាំងនេះ *ឌី.ស៊ី.ខេម*

បានស្នើសុំថតចម្លងពីបណ្ណសារដ្ឋានជាតិទាំងពីរនេះជាប្រយោជន៍ដល់ការស្រាវជ្រាវ ដោយសារឯកសារទាំងនេះចេញពីស្ថាប័នជាតិ មានអនុក្រឹត្យ មានភាពស្របច្បាប់ ហើយឯកសារថតចម្លងទាំងអស់ គឺ“ចម្លងចេញពីឯកសារដើម” ។[១៣] តាមដឹងមកថា ក្រសួងឃោសនាការ និងព័ត៌មាន បានរៀបចំទុកដាក់ឯកសារទាំងនេះមុនពេលបញ្ជូនទៅឲ្យបណ្ណសារដ្ឋានជាតិរក្សាទុក ។ សាក្សី **ឆាំង យុ** បានប្រៀបធៀបនូវចម្លើយសារភាព ដែលទទួលបានពីក្រសួងមហាផ្ទៃ និងចម្លើយសារភាពពីសារមន្ទីរទួលស្លែងដូចតទៅ៖ (ក) ច្បាប់ដើមនៃចម្លើយសារភាពពីទួលស្លែង គឺធ្វើលើអ្នកជាប់ឃុំឃាំងនៅទីនោះ រីឯចម្លើយសារភាពទទួលបានពីក្រសួងមហាផ្ទៃមានប្រភពចេញពីការិយាល័យសន្តិសុខមួយចំនួន (សន្តិបាល)[១៤] (ខ) យោងតាមរយៈបរិមាណ ឬប្រវែងនៃចម្លើយសារភាពចេញពីក្រសួងមហាផ្ទៃ គឺមានបរិមាណច្រើនជាងចម្លើយសារភាពបានពីបណ្ណសារដ្ឋានទួលស្លែង (គ) ចុងក្រោយបំផុត គឺទាក់ទងនឹងចំណារផ្សេងៗ គឺថាចំណារពីបុគ្គលច្រើននាក់ចំពោះឯកសារដែលបានពីក្រសួងមហាផ្ទៃ ប៉ុន្តែនៅទួលស្លែងឯនោះវិញ មានតែលោក **កាំងហ្គេចអ៊ាវ** ហៅ **ឌុច** ជាអ្នកដែលបានចារលើចម្លើយសារភាព ។

**ឯកសារទទួលបានពីប្រទេសស៊ុយអែត៖** មាន ៦ ទៅ ៧ម៉ឺនទំព័រត្រូវបានចងក្រងដោយគណៈកម្មការប្រទេសឡាវ ប្រទេសវៀតណាម ប្រទេសកម្ពុជា និងប្រទេសស៊ុយអែត (Sweden Friendship) ដែលប្រទេសទាំងនេះស្ថិតក្នុងអង្គភាពមួយដែលគាំទ្រដល់របបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៩ ។

**ការបរិចាកពីប្រភពឯកជននានា៖** លោក **ឆាំង យុ** បានថ្លែងថា *ឌី.ស៊ី.ខេម* ក៏បានទទួលឯកសារពីប្រភពឯកជនមួយចំនួនផងដែរដូចជាៈ ពីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លោក**ហ៊ុន សែន** ពីសាស្ត្រាចារ្យ **ឡូរ៉ា សាំម៉ឺស៍** ( Laura Summers) បណ្ឌិត **ហេលែន ចាវីស** (Dr. Helen Javis) លោក **គ្រេក អេជេសាន់** (Mr. Craig Etcheson) និងលោក **ដេវីដ ហាក** (Mr. David Hawk) ។ ក្រោយមក ពួកគេក៏បានផ្តល់ឲ្យ *ឌី.ស៊ី.ខេម* នូវសម្ភារៈផ្សេងៗមួយចំនួនទៀត ដូចជារូបថតពីមន្ទីរទួលស្លែង រូបថតពីទីតាំង រួមមានគុករណ្តៅសាកសពដែលលោក **ដេវីដ ហាក** ថតដោយខ្លួនឯង មានបញ្ជីឈ្មោះអ្នកទោស និងខ្សែអាត់សម្លេងមួយចំនួនផងដែរ ។

### *គ.៦. សេចក្តីចោទប្រកាន់ពីការគំរាមកំហែងលើសាក្សី*

លោក **ឆាំង យុ** បានបញ្ជាក់ថា កាលពីឆ្នាំ១៩៩៩ គាត់បានទទួលសំបុត្រមួយច្បាប់ពីលោកស្រី **អៀង ធីរិទ្ធ** ថាបានគំរាមគាត់ឲ្យឈប់ធ្វើការស្រាវជ្រាវរឿងរ៉ាវដែលកើតក្នុងរបបខ្មែរក្រហម ។ តាមដឹងមកថា បងស្រីរបស់លោក ក៏ត្រូវបានគេគំរាម បើទោះជាមិនបានដឹងច្បាស់ថាអ្នកណាជាអ្នកគំរាមក៏ដោយ និងបានប្រាប់លោកឲ្យឈប់ធ្វើការនេះទៀត ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីបានថ្លែងថា ការគំរាមកំហែងទាំងនេះមិនបានរារាំងគាត់បានទេ ហើយគាត់នៅតែបន្តការស្រាវជ្រាវ ។

## *ជំពូកទី៣ :* បញ្ហាផ្នែកច្បាប់ និងនីតិវិធី

បញ្ហានៃការប្រើប្រាស់ឯកសារនៅតែបន្តកើតមានអំឡុង៦សប្តាហ៍នៃសវនាការលើភស្តុតាង ។ បញ្ហាទី១ គឺស្តីពីយថាភាពនៃឯកសារបានពី *ឌី.ស៊ី.ខេម* ក៏ដូចជាខ្សែចង្វាក់នៃឯកសារទាំងនោះ ។ បញ្ហាមួយទៀត គឺទាក់ទងនឹងការប្រើប្រាស់ទម្រង់ព័ត៌មានរបស់ជនរងគ្រោះដើម្បីធ្វើការសួរដេញដោលលើសាក្សី ។ បញ្ហាផ្លូវច្បាប់ផ្សេងទៀតដែលធ្លាប់កើតមានរួចមកហើយនោះ បានកើតក្នុងសប្តាហ៍នេះ គឺទាក់ទងនឹងសិទ្ធិរបស់សាក្សីប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯង ។

មេធាវីការពារក្តីអន្តរជាតិរបស់លោក **អៀង សារី** គឺលោក **ម៉ៃខល កាណាវាស** បានជំទាស់នឹងសំណួរដែលសួរទៅកាន់សាក្សី **ប្រាក់ យុត** ក្រោមមូលដ្ឋានថា អ្នកស្រីអាចនឹងធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។ មេធាវីការពារក្តីអន្តរជាតិរបស់លោក **នួន ជា** គឺលោក **ម៉ៃខល ផេស្តមិន** ជាថ្មីម្តងទៀតបានលើកឡើងនូវការចោទប្រកាន់ស្តីពីការជ្រៀតជ្រែកផ្នែកនយោបាយលើតុលាការមួយនេះ ដោយគាត់បានផ្តល់យោបល់ថា សាក្សីត្រូវបានទទួលឥទ្ធិពល ឬការគំរាមកំហែង ។ ទំនាក់ទំនងមុនការចោទប្រកាន់ផ្សេងៗ ចំពោះថាមានការជ្រៀតជ្រែកពីផ្នែកនយោបាយ គឺបន្ទាប់ពីមានការថ្លែងការណ៍ជាសាធារណៈធ្វើឡើងនៅពេលវេលាខុសគ្នាដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺលោក **ហ៊ុន សែន** ។ អង្គជំនុំជម្រះ បានធានាដល់ភាគីថានៅពេលធ្វើសេចក្តីសម្រេចវាយតម្លៃនៃសំណុំរឿងនេះ អង្គចៅក្រមនឹងនៅតែរក្សាភាពមិនលម្អៀង ព្រមទាំងមិនពិចារណានូវការថ្លែងយោបល់ទាក់ទងនឹងរឿងនយោបាយ ដែលជាបញ្ហាក្រៅបន្ទប់សវនាការឡើយ ។

ចុងក្រោយ មានការជំទាស់ដដែលៗលើសំណួរដែលមិនស្ថិតក្នុងវិសាលភាពនៃការដឹងឮរបស់សាក្សី ឬក៏គោលបំណងដែលសាក្សីចូលខ្លួនមកផ្តល់សក្ខីកម្ម បូករួមទាំងការសួរសំណួរដែលមិនស្ថិតក្នុងដែនសមត្ថកិច្ចនៃសំណុំរឿងនេះ ។

### ក. យថាភាព និងភាពអាចជឿជាក់បាននៃឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា

បញ្ហាមួយ ក្នុងចំណោមឯកសារមួយចំនួនទៀតដែលបានកើតឡើងច្រើនជាងគេជាថ្មីក្នុងវិសាលភាពសំណុំរឿង០០២ ហើយបានក្លាយជាមូលហេតុនៃការជជែកតតាំងមិនឈប់ឈរ គឺបញ្ហាទាក់ទងនឹងប្រភេទឯកសារភស្តុតាងដែលត្រូវបានដាក់បង្ហាញក្នុងពេលសវនាការ និងដំណើរការដែលបានអនុវត្តក្នុងការផ្តល់យថាភាពក៏ដូចជាផ្តល់ការបញ្ជាក់លើឯកសារទាំងនេះ ។ ដើម្បីជួយដោះស្រាយភាពតានតឹងនេះ អង្គជំនុំជម្រះ បានកោះហៅតំណាងមកពី *ឌី.ស៊ី.ខេម* ចំនួនពីររូបមកផ្តល់សក្ខីកម្មដោយសារជាអង្គភាពដែលបានផ្តល់នូវប្រភពចម្បងនៃឯកសារដាក់ក្នុងសំណុំរឿងក្តី ។ ថ្វីបើមានការផ្តល់សក្ខីកម្មពីសាក្សីទាំងពីរក្តី ក៏ប្រភពដែលបានលើកឡើងខ្លះនៅតែមានភាពមិនទាន់ប្រាកដប្រជា ។ ឧទាហរណ៍ដូចជា ភាពមិនច្បាស់លាស់ថាតើឯកសារនៅក្នុងសំណុំរឿងដែលបានចាត់ទុកថាជាឯកសារភស្តុតាងត្រូវបានថតចម្លងចេញពីឯកសារ "ដើម" ឬគ្រាន់តែបានចម្លងតាមពីគំរូឯកសារដើម ដែលឯកសារប្រភេទនេះ *(បើតាមលោក **ឆាំង យុ** ក៏បានចាត់ទុកថាវាជាប្រភេទឯកសារ "ដើម" ដែរ ដោយសារវាបានសរសេរតាមឯកសារដើមដែលមិនអាចរកបាននៅប្រទេសកម្ពុជា)* ។ សំខាន់ជាងនេះទៅទៀត វានៅតែមិនទាន់ច្បាស់លាស់ថាតើការធានារបស់ *ឌី.ស៊ី.ខេម* ស្តីពីឆន្ទៈក្នុងការជួយអង្គជំនុំជម្រះដើម្បីធ្វើសេចក្តីបញ្ជាក់លើឯកសារ អាចបញ្ចូលទាំងការប្រៀបធៀបឯកសារចម្លងដែលកាន់កាប់ដោយតុលាការជាមួយនឹងឯកសារដើម ឬជាមួយឯកសារចម្លងចេញពីច្បាប់ "ដើម" ក្នុង

បណ្ណាល័យរបស់*ឌី.ស៊ី.ខេម* ឬយ៉ាងណា ។ បន្ថែមពីនេះទៀត សំណួរសួរថា តើ **អ.វ.ត.ក** បាន ឬមិនបាន ទាញយកឯកសារដើមតាមវិធីណានោះ នៅតែជាសំណួរនៅឡើយ ។

## ខ. ការអនុញ្ញាតសួរសំណួរយោងលើទម្រង់ព័ត៌មានរបស់ជនរងគ្រោះ

លោកប្រធាន **និល ណុន** បានរម្លឹកភាគីនៃអង្គជំនុំជម្រះស្ដីពីសេចក្ដីសម្រេចពីមុនក្នុងពេលធ្វើការសួរដេញដោលលើសាក្សីមួយចំនួន គឺភាគីមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់កំណត់ហេតុនៃសេចក្ដីថ្លែងការណ៍ផ្សេងៗ ឬក៏បទសម្ភាសន៍របស់សាក្សីមួយចំនួនជាសំអាងក្នុងការសួរឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កញ្ញា **ស៊ុតហ្ស៍** បានសុំការអនុញ្ញាតពីតុលាការដើម្បីយោងលើព័ត៌មានដែលមានក្នុងទម្រង់ដាក់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអានឲ្យសាក្សី **ប្រាក់ យុត** ស្ដាប់មុនសួរ ។ មេធាវី **ស៊ុតហ្ស៍** បានធ្វើអំណះអំណាងពីភាពត្រឹមត្រូវនៃការស្នើរបស់ខ្លួន ដោយចង្អុលបង្ហាញថា នៅក្នុងទម្រង់ដែលខ្លួនចង់ប្រើដើម្បីសួរ គឺមានទំនាក់ទំនងជាក់លាក់នឹងសាក្សី **ប្រាក់ យុត** ។ បន្ទាប់ពីការពិគ្រោះយោបល់ខ្លះរវាងអង្គចៅក្រម អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចថា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងមិនត្រូវអនុញ្ញាតឲ្យប្រើប្រាស់ទម្រង់ព័ត៌មានរបស់ជនរងគ្រោះដែលមានតែភាសាខ្មែរ (*បើទោះជាមានការសង្ខេបជាភាសាអង់គ្លេស*) យកមកធ្វើការសួរដេញដោលលើសាក្សីបានទេ ។ អង្គចៅក្រមបានពន្យល់ថា បម្រាមនេះត្រូវបានចុះនៅក្នុងអនុស្សរណៈថា ការខកខានរបស់ភាគីក្នុងការធានានូវការបកប្រែឯកសារដែលខ្លួនចង់ប្រើប្រាស់ឲ្យបានទាន់ពេលវេលា គឺអាចរឹតត្បិតលទ្ធភាពរបស់ខ្លួនក្នុងការប្រើប្រាស់ឯកសារនោះ។[១៥]

សហមេធាវីនាំមុខអន្តរជាតិ គឺលោកស្រី **ស៊ីម៉ូណូ ហ្សូត** បានកត់សម្គាល់ថា ការបកប្រែនូវទម្រង់ព័ត៌មានជនរងគ្រោះមិនត្រូវបានអនុញ្ញាតទេ ព្រោះតែវាមិនអាចធ្វើទៅរួចនូវចំនួនដ៏ច្រើននៃឯកសារ មានប្រមាណ៨ពាន់ច្បាប់ គួរតែត្រូវបានបកប្រែដោយអង្គភាពបកប្រែភាសារបស់ **អ.វ.ត.ក** ។ លោកស្រីបានតវ៉ាថា ការិយាល័យសហព្រះរាជអាជ្ញា និងអង្គបុរេជំនុំជម្រះ បានព្រមទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជិត៨ពាន់នាក់ (*ដូច្នេះមានឯកសារជិត៨ពាន់ច្បាប់ដែរ*) ថាពាក្យសុំទាំងនេះមានយថាភាព និងអាចជឿជាក់បាន ។ លោកស្រី **ស៊ីម៉ូណូ ហ្សូត** បានបន្ដគូសបញ្ជាក់នូវសារៈសំខាន់នៃការអនុញ្ញាតឲ្យប្រើប្រាស់ឯកសារជាទម្រង់ព័ត៌មានទាំងនេះ ។ នៅក្នុងសេចក្ដីបន្ថែមលើកំណត់ត្រានេះ លោកស្រីបានផ្ដល់យោបល់ដល់តុលាការថា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានចេតនាដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះក្នុងដំណើរការនីតិវិធីជាបន្ដបន្ទាប់ទៀត ។ បន្ទាប់ពីបានពិគ្រោះយោបល់រវាងអង្គចៅក្រមរួចមក ប្រធានតុលាការ ចៅក្រម **និល ណុន** បានរម្លឹកជាថ្មីថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យប្រើទម្រង់ព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើជាគោលក្នុងការសួរសំណួរទេ ដោយសារថាទម្រង់ទាំងនេះមានតែមួយភាសាប៉ុណ្ណោះ។ ចប់ការថ្លែង លោកប្រធានក៏បានប្រកាសផ្អាកសវនាការ ។ ប្រការនេះនៅតែធ្វើឲ្យមានភាពស្រពេចស្រពិលមិនដឹងថា អង្គជំនុំជម្រះនឹងសម្រេចដូចម្ដេចប្រសិនបើទម្រង់ព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលយ៉ាងហោចណាស់ពីរភាសាដែល **អ.វ.ត.ក** បាននឹងកំពុងប្រើប្រាស់ ។

## គ. សិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង

បន្ទាប់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំអនុញ្ញាតឲ្យប្រើទម្រង់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីយោងលើការសួរដេញដោលចំពោះសាក្សី **ប្រាក់ យុត** មេធាវីអន្តរជាតិការពារក្តីលោក **អៀង សារី** គឺលោក **ម៉ៃខល កាណាវ៉ាស** បានជំទាស់ និងតវ៉ាថា សំណួរដែលបានសួរហាក់មិនបង្ហាញគោលបំណងច្បាស់លាស់ ក្រៅតែពីការចង់បង្កើតនូវសក្ខីកម្មដែលឲ្យសាក្សីឆ្លើយនូវសំណួរប្រឆាំងនឹងខ្លួនឯង ។ លោក **កាណាវ៉ាស** បានស្នើឲ្យអង្គជំនុំជម្រះក្រើនរម្លឹកទៅដល់សាក្សីអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបចំពោះសំណួរប្រភេទនេះ ។ មេធាវី **ស៊ុតហ្ស៍** បានឆ្លើយតបថា គោលបំណងរបស់កញ្ញា គឺមិនមែនចង់ឲ្យសាក្សីផ្តល់នូវសក្ខីកម្មប្រឆាំងនឹងខ្លួនឯងនោះទេ ប៉ុន្តែកញ្ញាមានចេតនាបង្កើតនូវភាពស៊ីចង្វាក់នៃបទបញ្ជា និងដើម្បីធ្វើការកំណត់ថាតើសាក្សីបានទទួលបទបញ្ជាពីថ្នាក់លើណាមួយឲ្យបញ្ជូនមនុស្សទៅទីតាំងពិឃាតដែរឬទេ ។

មុនពេលអង្គជំនុំជម្រះអាចធ្វើការសម្រេចលើសេចក្តីជំទាស់នេះ សាក្សី **ប្រាក់ យុត** បានឆ្លើយតបថា នៅពេលដែលអ្នកស្រីធ្វើការងារអប់រំដល់ប្រជាជនក្នុងស្រុក*កំពង់សៀម* គាត់មិនបានបញ្ជូនបុគ្គលណាមួយទៅសម្លាប់នៅ*ភ្នំប្រុសភ្នំស្រី* ទេ។ អ្នកស្រីបានបញ្ជាក់ថា ចម្លើយរបស់អ្នកស្រីដូចនេះ ធ្វើក្នុងនាមជាសាក្សីម្នាក់មិនទាក់ទងអ្វីនឹងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបឡើយ តែអ្នកស្រីគ្រាន់តែចង់បញ្ជាក់ថា ខ្លួនមិនបានដឹងឮថាមានការសម្លាប់នៅតំបន់នោះ ។ អ្នកស្រី **ប្រាក់ យុត** ក៏បានពន្យល់ផងដែរថា អ្នកស្រីបានសុំឲ្យភាគីអ្នកសួរធ្វើការបញ្ជាក់នៅពេលដែលអ្នកស្រីមិនយល់សំណួរ ។

សិទ្ធិរបស់សាក្សីក្នុងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺត្រូវបានចែងមិនតិចជាង៥ចំណុចតូចៗឡើយនៅក្នុងវិធានផ្ទៃក្នុងរបស់ **អ.វ.ត.ក** លេខ២៨ ។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះបានបង្ហាញពីការប្រុងប្រយ័ត្នដើម្បីការពារសិទ្ធិរបស់សាក្សីទាំងឡាយដែលបានចូលខ្លួនមកផ្តល់សក្ខីកម្ម ដោយមិនត្រឹមតែប្រាប់ឲ្យដឹងពីសិទ្ធិដែលពួកគេត្រូវទទួលបាននោះទេ ប៉ុន្តែសំខាន់ជាងនេះទៀត គឺបានខិតខំប្រឹងប្រែងធានាថា សាក្សីទាំងអស់យល់ពីសិទ្ធិទាំងនេះ ។ កិច្ចខិតខំប្រឹងប្រែងដើម្បីការពារសាក្សី ក៏ដូចជាចំណាត់ការទាំងឡាយនៅតែបន្តរហូតបច្ចុប្បន្ននេះ ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះបានចាត់តាំងមេធាវីម្នាក់ដើម្បីជួយផ្តល់ប្រឹក្សាដល់សាក្សីទាំងឡាយ ដែលមានការប្រឈមមុខនឹងការផ្តល់សក្ខីកម្មដែលអាចប្រឆាំងនឹងខ្លួនឯង។[១៦]

## ឃ. ការចោទប្រកាន់ស្តីពីការជ្រៀតជ្រែកផ្នែកនយោបាយ និងសិទ្ធិភាគីការពារក្តីទាក់ទងនឹងការជ្រើសយកវិធីសាស្ត្រសួរដេញដោលសាក្សី

បញ្ហានៃការជ្រៀតជ្រែកផ្នែកនយោបាយក្នុងសំណុំរឿង០០២ ត្រូវបានលើកឡើងពីរដងក្នុងសប្តាហ៍នេះ ។ លើកទី១ ត្រូវបានកើតឡើងនៅពេលមេធាវីការពារក្តីលោក **នួន ជា** ធ្វើការសួរដេញដោលសាក្សី **ប្រាក់ យុត** ហើយលើកទី២ ត្រូវបានកើតឡើងនៅពេលអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចលើការស្នើសុំពីមុនដែលបានដាក់ជូនក្នុងអំឡុងបីសប្តាហ៍មុន ពីសំណាក់មេធាវីក្រុមដដែលនេះស្តីពីការថ្កោលទោសលោក **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការដែលលោកនាយករដ្ឋមន្ត្រីបានធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងជនជាប់ចោទ **នួន ជា** ដល់អ្នកសារព័ត៌មាន ។

### ឃ.១. ការស្នើផ្សេងៗចំពោះអង្គហេតុថាមានការគំរាមកំហែងដល់សាក្សី

នៅពេលមេធាវី **ផេស្តមិន** ត្រូវបានផ្តល់ឱកាសឲ្យសួរដេញដោលសាក្សី **ប្រាក់ យុត** មេធាវីបានសួរអ្នកស្រីអំពីឈ្មោះ **តាអាន** និងអ្នកស្រី **អ៊ឹម ចែម** ។ ដែលអ្នកទាំងពីរនេះត្រូវបានដឹងពីព័ត៌មានមិនផ្លូវការតាមរយៈបទរាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយថាមានឈ្មោះក្នុងបញ្ជីឈ្មោះជនសង្ស័យនៃសំណុំរឿង០០៤។[១៧]

ដូចបានចង្អុលបង្ហាញពីខាងដើមមកហើយថា សាក្សី **ប្រាក់ យុត** បានទទួលស្គាល់ថាអ្នកស្រីធ្លាប់បានធ្វើការជាមួយបុគ្គលទាំងពីររូបនេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនមានការទាក់ទងគ្នាបន្ទាប់ពីឆ្នាំ១៩៧៩ មកម្ល៉េះ ។ មេធាវី **ផេស្តមិន** បានចោទប្រកាន់ថា សាក្សីមានការរួញរាក្នុងការផ្តល់សក្ខីកម្ម និងបានថ្លែងថា អ្នកស្រីប្រហែលជាបាទទួលរងនូវឥទ្ធិពល ឬការគំរាមសម្លុតណាមួយ ។ អ្នកស្រី **ប្រាក់ យុត** បានជំទាស់ដាច់អហង្ការនូវការចោទប្រកាន់របស់មេធាវី **ផេស្តមិន** ថែមទាំងបានធានាអង្គជំនុំជម្រះថា អ្នកស្រីបានប្រាប់តុលាការតែអ្វីដែលជាការពិត និងតែពីអ្វីដែលអ្នកស្រីបានដឹងឮ ។ អង្គជំនុំជម្រះ បានណែនាំម្តងហើយម្តងទៀតដល់មេធាវី **ផេស្តមិន** ឲ្យរៀបចំសំណួររបស់ខ្លួនតែត្រឹមវិសាលភាពនៃសំណុំរឿងដែលអង្គជំនុំជម្រះបានកំណត់ ។ ទោះជាយ៉ាងនេះក្តី មេធាវី **ផេស្តមិន** នៅតែបន្តសួរសាក្សីបន្ថែមទៀត ថាតើអ្នកស្រីបានឮ ឬដឹងអំពីសំណុំរឿង០០៤ ដែរឬទេ ហើយតើអ្នកស្រីបានដឹងទេថា **តា អាន** និងអ្នកស្រី **អ៊ឹម ចែម** ជាជនសង្ស័យនៃសំណុំរឿង០០៤ ។ សាក្សី **ប្រាក់ យុត** បានបដិសេធមិនដឹងឮចំពោះបញ្ហានេះ ។ មេធាវីក៏បានសួរផងដែរថាតើមានភាគីទីបីណាមួយបានទៅជួបអ្នកស្រីមុន ដើម្បីឲ្យចូលបង្ហាញខ្លួននៅចំពោះមុខ **អ.វ.ត.ក** ដែរ ឬទេ ហើយនិងបានសួរទៀតថា តើអ្នកស្រីបានដឹងទេថា រាជរដ្ឋាភិបាលបានជំទាស់មិនឲ្យមានសវនាការលើសំណុំរឿង០០៤ ។ លោក **ផេស្តមិន** បានផ្ចាញ់ពីការជឿជាក់របស់សាក្សីនេះដោយថា អ្នកស្រីបានដឹងថារដ្ឋាភិបាលមិនចង់ឲ្យមានសវនាការនីតិវិធីលើសំណុំរឿង០០៤ ចេញជារូបរាងទេ ដែលប្រការនេះហើយធ្វើឲ្យអ្នកស្រីស្ទាក់ស្ទើរក្នុងការផ្តល់សក្ខីកម្មអំពីបុគ្គលមួយចំនួនដែលត្រូវបានស៊ើបអង្កេតក្នុងសំណុំរឿង០០៤ ។ ក្រោយមក លោកមេធាវីបានពណ៌នាអ្នកស្រីថាជាសាក្សីម្នាក់ ដែលមិនអាចជឿជាក់បាន ។ ការលើកឡើងនេះ នាំឲ្យអង្គចៅក្រមធ្វើអន្តរាគមន៍តាមរយៈចៅក្រម **ស៊ីលវៀរ ខាតវ៉ៃយច៍** ។ លោកស្រី បានសួរទៅកាន់សាក្សីថាតើសាក្សីពិតជាបានទទួលរងសម្ពាធ ហើយតើសាក្សីកំពុងតែប្រាប់តុលាការពីការពិតដែរឬទេ ។ ក្នុងការឆ្លើយតប សាក្សីបានប្រាប់ម្តងទៀតថា អ្នកស្រីបានឆ្លើយគ្រប់យ៉ាងដោយសេរីដល់គ្រប់ភាគីនៃ **អ.វ.ត.ក** ពីអ្វីដែលអ្នកស្រីបានដឹង ហើយថាអ្នកស្រីមិនបានទទួលរងនូវការសម្លុតគំរាម ហើយក៏មិនមានអ្នកណាម្នាក់បង្រៀនឲ្យអ្នកស្រីផ្តល់សក្ខីកម្មខុសពីឆន្ទៈដែរ ។ មេធាវី **ផេស្តមិន** បានបង្ហាញពីភាពទោមនស្សចំពោះការធ្វើអន្តរាគមន៍ពីសំណាក់អង្គជំនុំជម្រះ និងបានតវ៉ាថា ភាគីការពារក្តីលោក **នួន ជា** មានសិទ្ធិ និងកាតព្វកិច្ចក្នុងការតទល់នឹងភាពគួរជឿជាក់បាននៃសាក្សីនេះ ដោយមិនចាំបាច់មានការលូកដៃពីចៅក្រម "ដោយយើងយល់ថាសាក្សីមិនបានបង្ហាញការពិតទាំងស្រុងនោះទេ ហើយចៅក្រមក៏ទំនងជាមិនមានសិទ្ធិក្នុងការជួយសង្គ្រោះសាក្សីក្នុងស្ថានភាពបែបនេះបានទេ"។[១៨] ក្រុមមេធាវីការពារក្តី លោក **នួន ជា** បានសង្កត់ធ្ងន់ថា ក្នុងនាមខ្លួនជាមេធាវីការពារក្តី ខ្លួនមានសិទ្ធិក្នុងការសម្រេចជ្រើសយកវិធីណាមួយដើម្បីការពារក្តីឲ្យលោក **នួន ជា** ដរាបណាវាស្ថិតនៅក្នុងរង្វង់អំណាចច្បាប់ និងដោយសារសិទ្ធិរបស់ជនជាប់ចោទមានដោយច្បាប់នោះ ។ លោក **ផេស្តមិន** បានថ្លែងថាការធ្វើកំណត់សម្គាល់របស់ចៅក្រម **ខាតវ៉ៃយច៍** ថា "មិនសមស្រប" ហើយថាចៅក្រមមិនគួររំខានដល់យុទ្ធសាស្ត្ររបស់មេធាវីការពារក្តីនោះទេ ។ សហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក **ខេល លីសាក់** ក៏ជាអ្នក

ដែលបានជំទាស់នឹងខ្សែសំណួររបស់មេធាវី **ផេស្គមិន** ដែររនោះ បានសម្ដែងនូវការមិនយល់ស្របចំពោះយោបល់ថ្លែងដោយមេធាវី **ផេស្គមិន** ។ លោក **លីសាក់** បានតវ៉ាថា វាជាប្រការសមស្របណាស់ចំពោះអង្គជំនុំជម្រះក្នុងការលូកដៃចូលតាមរយៈការសួរសំណួរផ្ទាល់ទៅកាន់សាក្សី ជាពិសេសបន្ទាប់ភាគីការពារក្ដីបានចោទប្រកាន់ថាអ្នកស្រីមិនមានភាពស្មោះត្រង់ ។

### *ឃ.២. ការឆ្លើយតបរបស់អង្គជំនុំជម្រះចំពោះការស្នើរបស់មេធាវី ផេស្គមិន ទាក់ទងនឹងសេចក្ដីថ្លែងការណ៍ចោទប្រកាន់ពីសំណាក់នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រឆាំងលើលោក នួន ជា*

កាលពីថ្ងៃទី១០ ខែមករា មេធាវីការពារក្ដីលោក **នួន ជា** បានលើកឡើងនូវបញ្ហានៃការចោទប្រកាន់ពីសំណាក់លោក **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយវៀតណាម ដោយគាត់ត្រូវបានគេស្រង់សម្ដីថាបានហៅលោក **នួន ជា** ថាជាជន "បោកប្រាស់" ជា "មេឃាតករ" និងជាជនក្បត់ក្នុងរបបប្រល័យពូជសាសន៍ ។ មេធាវី **ផេស្គមិន** បានស្នើសុំឲ្យអង្គជំនុំជម្រះ ធ្វើការថ្កោលទោសចំពោះការធ្វើសេចក្ដីថ្លែងការណ៍បែបនេះ និងស្នើដល់លោកនាយករដ្ឋមន្ត្រីឲ្យបញ្ឈប់ការបន្តធ្វើសេចក្ដីថ្លែងការណ៍ប្រភេទនេះតទៅទៀត ។ លោក **ផេស្គមិន** បានតាមដាននូវការស្នើរបស់ខ្លួនកាលពីថ្ងៃទី១៩ ខែមករា ប៉ុន្តែអង្គជំនុំជម្រះនិយាយថា នឹងមិនធ្វើការផ្ដល់យោបល់ណាមួយទៅលើការថ្លែងរបស់នាយករដ្ឋមន្ត្រីនោះទេ ហើយក៏មិនហាមឃាត់នូវការលើកឡើងជាថ្មីម្ដងទៀតដែរ ។ ទោះជាយ៉ាងណាក៏ដោយ កាលពីថ្ងៃព្រហស្បតិ៍សប្ដាហ៍នេះ អង្គជំនុំជម្រះបានឆ្លើយតបយ៉ាងខ្លី ចំពោះសំណើរបស់មេធាវី **ផេស្គមិន** ។ អង្គជំនុំជម្រះបានស្រង់នូវមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលផ្ដល់នូវការសន្មតពីភាពគ្មានទោសរបស់ជនជាប់ចោទដោយបានធ្វើការធានាចំពោះភាគីថា វាគឺជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គជំនុំជម្រះក្នុងការសម្រេចថាជនជាប់ចោទណាមានពិរុទ្ធភាព ឬគ្មាន ។ អង្គជំនុំជម្រះ បានសង្កត់ធ្ងន់ថា ការធ្វើដូចនេះ វាតម្រូវឲ្យមានការពិចារណានូវអង្គហេតុពាក់ព័ន្ធទាំងភស្តុតាង ទាំងការស្នើផ្សេងៗ ក៏ដូចជាច្បាប់មួយចំនួនដែលអាចយកមកប្រើប្រាស់បាន ។ តុលាការក៏បានធានាបន្តទៀតថា រាល់ការលើកឡើងជាយោបល់ពីសាធារណជនក្រៅពីបន្ទប់តុលាការនឹងមិនត្រូវបានយកមកពិចារណានៅក្នុងសេចក្ដីសម្រេចរឿងក្ដីឡើយ ។

តាំងពីដើមដល់ចប់សវនាការសប្ដាហ៍នេះ មេធាវីការពារក្ដីលោក **នួន ជា** បានលើកឡើងម្ដងហើយម្ដងទៀត ដោយថ្កោលទោសលើការជ្រៀតជ្រែកនយោបាយ ។ ក្រុមការពារក្ដី ក៏បានដាក់បណ្ដឹងទៅសាលាដំបូងរាជធានីភ្នំពេញ ចំពោះការជ្រៀតជ្រែកនយោបាយប្រឆាំងនឹងមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលមួយចំនួន ។ ទោះជាយ៉ាងនេះក្ដី មេធាវីក្រុមនេះ មិនមានឱកាសធ្វើការបំភ្លឺឲ្យឃើញនូវគោលជំហររបស់ពួកគេអំឡុងពេលសវនាការនោះទេ ដែលតាមស្មានប្រហែលជាមកពីការចោទប្រកាន់ស្ដីពីការជ្រៀតជ្រែកក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ។

## ង. ការជំទាស់ទៅនឹងសំណួរក្រៅវិសាលភាពនៃការកំណត់របស់អង្គជំនុំជម្រះ

សប្ដាហ៍នេះ យើងឃើញមានការជំទាស់មួយចំនួនកើតឡើងសាជាថ្មី ទាក់ទងនឹងសំណួរដែលបានសួរក្នុងបន្ទប់តុលាការ ថាស្ថិតនៅក្រៅវិសាលភាពនៃចំណេះដឹងរបស់សាក្សី ក្រៅវិសាលភាពនៃដែនកំណត់សវនាការវគ្គនេះ ក៏ដូចជាខុសពីគោលបំណងនៃការស្ដាប់សក្ខីកម្មរបស់សាក្សីទាំងឡាយដែលបានចូលខ្លួនឆ្លើយក្នុងសប្ដាហ៍នេះជាដើម ។ បើគ្រាន់តែគិតត្រឹមថ្ងៃច័ន្ទ មានឧទាហរណ៍ស្ដីពីហេតុការចំនួនពីរយ៉ាងតិច

បានកើតឡើង។ ឧទាហរណ៍ទី១ គឺនៅពេលមេធាវី **កាណាវាស** បានធ្វើការជំទាស់នឹងសំណួរសួរលើសាក្សី **ប្រាក់ យុត** ដោយមេធាវី **ស៊ិតហ្ស៍** ក្រោមហេតុផលថា សំណួរទាំងនោះនៅក្រៅព្រំដែនសវនាការ ។ ក្រោយៗមកទៀត អង្គជំនុំជម្រះបានលើកហេតុផលដូចគ្នានេះ ដើម្បីរម្លឹកដល់មេធាវី **ផេស្តមិន** មិនឲ្យសួរសំណួរទាំងឡាយណាដែលគ្មានប្រភពអះអាងស្តីពីជនសង្ស័យក្នុងសំណុំរឿង០០៤ ។

កាលពីព្រឹកថ្ងៃព្រហស្បតិ៍ មេធាវី **វែកតែន** បានសួរទៅកាន់សាក្សី **ប្រាក់ យុត** ថាតើនៅពេលកំពុងផ្តល់បទសម្ភាសន៍ឲ្យចៅក្រមស៊ើបអង្កេត វាជាការអនុវត្តដ៏ល្អក្នុងការយោងលើឯកសារដើម ជាជាងឯកសារបានពីការថតចម្លង ឬយ៉ាងណា ។ សហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក **ថារិក អាប់ឌុលហាក់** បានជំទាស់នឹងសំណួរសួរនេះ ក្រោមហេតុផលថា វាមិនស្ថិតក្នុងដែនបំណងនៃការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ ។ គាត់បានតវ៉ាថា វាក៏ស្ថិតនៅក្រៅជំនាញរបស់សាក្សីផងដែរ ពីព្រោះវាបានកោះកកាយនូវការសន្និដ្ឋានផ្លូវច្បាប់មួយដែលជាការងាររបស់ចៅក្រម មិនមែនជាសាក្សីទេ ។ មេធាវី **វែកតែន** បានឆ្លើយតបថា គាត់មិនបានសួរពីកិច្ចការស៊ើបអង្កេតរបស់តុលាការទេ ដោយសារតែសាក្សីបានប្រើពាក្យ “ស៊ើបអង្កេត” ដើម្បីពណ៌នាពីការងាររបស់*ឌី.ស៊ី.ខេម(ឌី.ស៊ី.ខេម មិនអាចមានភារៈដូចចៅក្រមស៊ើបទេ)* ។ អង្គជំនុំជម្រះ បានសម្រេចឯកភាពលើការជំទាស់របស់ភាគីសហព្រះរាជអាជ្ញា ដោយយោងលើហេតុផលថា សំណួររបស់មេធាវី **វែកតែន** មិនមានមូលដ្ឋាន ព្រោះថា*ឌី.ស៊ី.ខេម* មិនបានធ្វើកិច្ចការអ្វីដែលទាក់ទងនឹងដំណើរការតុលាការទេ ។ មេធាវី **វែកតែន** បានតវ៉ាថា សំណួរទាំងនេះមានសារៈសំខាន់ណាស់ ព្រោះឯកសារមួយភាគធំនៅក្នុងសំណុំរឿង ត្រូវបានប្រមែប្រមូលដោយ *ឌី.ស៊ី.ខេម* ហើយភាគីសហព្រះរាជអាជ្ញាបានឲ្យទម្ងន់លើឯកសារទាំងនេះរួចហើយ ដោយមិនមានការផ្ទៀងផ្ទាត់បន្ថែមឡើយ ។

ភាពមិនស្រុះស្រួលគ្នាពីគោលបំណងអ្វីទៅ ដែលអង្គជំនុំជម្រះបានសម្រេចកោះហៅលោក **ឆាំង យុ** មកផ្តល់សក្ខីកម្មនេះ ហាក់ដូចជាដើមចមនាំឲ្យមានការជំទាស់មួយចំនួនពីសំណាក់ភាគីសហព្រះរាជអាជ្ញា **អាប់ឌុលហាក់** នៅក្នុងពេលលោក **ចាស្ទី ប៉ៅ** មេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** បានសួរដេញដោលដោយលើសាក្សី ។ ខណៈដែលលោក **អាប់ឌុលហាក់** បានតវ៉ាថា សាក្សីបានមកផ្តល់សក្ខីកម្មតែពីវិធីសាស្ត្រក្នុងការទទួលបានឯកសារ ការរៀបចំបញ្ជីឈ្មោះឯកសារ (*រៀបកាតាឡុក*) និងការរក្សាទុកឯកសារ ហើយជាក់លាក់ជាងនេះទៀតគឺថា រាល់ឯកសារដែលស្ថិតនៅក្នុងសំណុំឯកសារតុលាការ មេធាវី **ប៉ៅ** បានច្រានចោលនូវការថ្លែងរបស់ព្រះរាជអាជ្ញាដោយថ្លែងថា សាក្សី **ឆាំង យុ** ត្រូវតែបានសួរនាំពីគោលដៅក្នុងការបង្កើតនូវមជ្ឈមណ្ឌលឯកសារមួយនេះ ដោយសារ *ឌី.ស៊ី.ខេម* មានតួនាទីដ៏សំខាន់សម្រាប់សំណុំរឿង ហើយលោកថា លោកក៏ស្វែងយល់ផងដែរអំពីលក្ខខណ្ឌដែល *ឌី.ស៊ី.ខេម* ប្រើប្រាស់នៅពេលធ្វើការសម្រេចថាតើឯកសារណាមួយត្រូវបញ្ចូលទៅក្នុងចំណាត់ថ្នាក់ឯកសារនីមួយៗ ។

តាមរយៈសំណួរមួយចំនួនរបស់គាត់ មេធាវី **ប៉ៅ** បានព្យាយាមបង្ហាញថាគោលជំហររបស់*ឌី.ស៊ី.ខេម* មិនមានលក្ខណៈអព្យាក្រិត្យក្នុងការប្រមូលឯកសារនោះទេ ប៉ុន្តែបានខិតខំប្រមូលតែលើឯកសារណាដែលប្រឆាំងនឹងបុគ្គលពាក់ព័ន្ធជាក់លាក់មួយចំនួន បូករួមទាំងកូនក្តីរបស់គាត់ លោក **នួន ជា** ផងដែរ ។ អង្គជំនុំជម្រះបានហាមឃាត់មេធាវី **ប៉ៅ** មិនឲ្យបន្តសួរនូវចង្វាក់សំណួរបែបនេះទេ ។ ចៅក្រម **ខាតរ៉ែយថ៍** បានពន្យល់ថា អង្គជំនុំជម្រះបានយល់អំពីហេតុផលនៃការសួរសំណួររបស់មេធាវី បូករួមទាំងការមិនជឿជាក់របស់គាត់ចំពោះវិធីសាស្ត្ររបស់*ឌី.ស៊ី.ខេម* ប៉ុន្តែអង្គជំនុំជម្រះបានឮគ្រប់គ្រាន់ហើយអំពីប្រធានបទនេះ ។

## *ជំពូកទី៤ :* **ការគ្រប់គ្រងសវនាការ**

អង្គជំនុំជម្រះបានពើបប្រទះនូវបញ្ហានៃការគ្រប់គ្រងសវនាការមិនអស់មិនហើយក្នុងសប្តាហ៍នេះ ជាពិសេស ការខិតខំធ្វើឲ្យមានបរិយាកាសល្អក្នុងបន្ទប់សវនាការ ក្នុងអំឡុងពេលដំណើរការនីតិវិធី ហើយក៏ប្រឈមផងដែរជាមួយនឹងបរិក្ខារប្រើប្រាស់ក្នុងការបកប្រែ ។

### ក. វត្តមាន

ជនជាប់ចោទទាំងអស់ មានវត្តមានក្នុងបន្ទប់សវនាការតាំងពីដើមដល់ចប់សវនាការសប្តាហ៍នេះ។ ទោះជាយ៉ាងនេះក្តី ជារៀងរាល់ថ្ងៃ លោក **អៀង សារី** តែងតែធ្វើការស្នើសុំទៅតាមដានសវនាការពីចម្ងាយនៅបន្ទប់សោតទស្សន៍បន្ទាប់ពីចប់សវនាការវគ្គទី១ ហើយលោក **នួន ជា** បានធ្វើដូចគ្នាបន្ទាប់ពីចប់សវនាការវគ្គទី២។ មានតែជនជាប់ចោទ **ខៀវ សំផន** តែម្នាក់គត់ដែលបានបង្ហាញខ្លួនក្នុងបន្ទប់សវនាការរៀងរាល់វគ្គទាំងអស់នៃដំណើរការនីតិវិធីក្នុងសប្តាហ៍នេះ ។ គួរកត់សម្គាល់ផងដែរថា កាលពីសវនាការមុនៗ មិនមានវត្តមានមេធាវីអន្តរជាតិតំណាងឲ្យលោក**ខៀវ សំផន** ក្នុងបន្ទប់សវនាការទេ ប៉ុន្តែទើបតែមានសាជាថ្មីក្នុងសប្តាហ៍នេះ។ លោកមេធាវីមានឈ្មោះថា **អាកទូរ វែកគែន** ។ គាត់បានបង្ហាញខ្លួនពេញមួយសប្តាហ៍ ។

***វត្តមានរបស់ភាគី:*** មានចំនួនអ្នកចូលរួមតាមដានសវនាការច្រើនក្នុងសប្តាហ៍នេះ ។ អ្នកចូលរួមភាគច្រើនជាសិស្សានុសិស្សពីវិទ្យាល័យ (អាយុចាប់ពី១៦ ទៅ១៨ឆ្នាំ) ។ កាលពីថ្ងៃច័ន្ទ មានសិស្សានុសិស្សប្រមាណជា ២០០នាក់ មកពី*វិទ្យាល័យឥន្ទ្រៈទេវី* នៃទីក្រុងភ្នំពេញបានចូលរួមពេញមួយថ្ងៃ ។ ថ្ងៃអង្គារ មានសិស្សានុសិស្សប្រមានជា ៣០០នាក់មកពី*វិទ្យាល័យវត្តភ្នំ* នៃទីក្រុងភ្នំពេញ បានចូលរួមក្នុងវគ្គពេលព្រឹក ។ នៅថ្ងៃពុធ វិញ មានសិស្សានុសិស្សប្រមាណជា ៣០០នាក់ពី*វិទ្យាល័យជ័យវរ្ម័នទី៧* នៃខេត្តកណ្តាល បានតាមដានសវនាការពេញមួយថ្ងៃ ។ ចុងក្រោយបំផុត គឺថ្ងៃព្រហស្បតិ៍ មានប្រជាពលរដ្ឋប្រមាណជា៣០០នាក់មកពីខេត្តតាកែវ បានចូលរួម ។

### ខ. បរិយាកាសក្នុងបន្ទប់សវនាការ

ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម សាក្សី **ផាំង យុ** បានបង្ហាញនូវកម្រិតនៃការប្រឆាំងតទល់បែបចំអកឡកឡឺយឲ្យមេធាវីការពារក្តីដែលហេតុការណ៍នោះ នាំឲ្យមានការអន្តរាគមន៍ពីសំណាក់ប្រធានតុលាការ ។ ជាឧទាហរណ៍ បន្ទាប់ពីសាក្សីបានឆ្លើយនូវសំណួរមួយចំនួនពីមេធាវីជាតិការពារក្តីលោក **ខៀវ សំផន** គឺលោកមេធាវី **គង់ សំអុន** ស្តីពីនីតិវិធីរបស់*ឌី.ស៊ី.ខេម* និងការរៀបរៀងបញ្ជីឯកសារនានា សាក្សីបានផ្តល់យោបល់ថា "ជាទូទៅបើលោកបានឆ្លងកាត់ការសិក្សារៀនសូត្រនៅក្នុងសាកលវិទ្យាល័យ ឬមហាវិទ្យាល័យនេះ វាជារឿងសាមញ្ញគឺថា ដើម្បីធ្វើការសិក្សាស្រាវជ្រាវមួយ យើងត្រូវមានឯកសារជាពីរលំដាប់ ។ ហើយខ្ញុំគិតថាលោកបានបញ្ចប់ការសិក្សាហើយ ហើយក្លាយជាមេធាវីដែលមានមុខនាទីនៅទីនេះទៀត" ។[១៥] លោក **ផាំង យុ** បានបន្តពន្យល់ជាហូរហែស្តីពីប្រភេទឯកសារទាំងពីរលំដាប់នេះប្រើដើម្បីស្រាវជ្រាវ គឺមានឯកសារដើម និងឯកសារបន្ទាប់បន្សំ ហើយលោកថែមទាំងបានបញ្ជាក់ថា "ឯកសារពីរលំដាប់នេះ គឺជាប្រព័ន្ធសិក្សារៀនសូត្រនៅគ្រប់មហាវិទ្យាល័យទាំងអស់ ទាំងស្រុកយើងក្តី អាមេរិកក្តី បារាំងក្តី គឺជារឿងសាមញ្ញសម្រាប់អ្នកណាដែល

បានរៀនសូត្រ គឺសុទ្ធតែស្គាល់ឯកសារទាំងពីរលំដាប់នេះ” ។ នៅពេលមេធាវី **គង់ សំអុន** ចង់ឆ្លើយតបនឹងការលើកយោបល់របៀបនេះ សាក្សីបានបន្តនិយាយថា “សូមទោស លោកយល់ខ្ញុំឆ្លើយទៅទេ” ។[២០] មេធាវី **គង់ សំអុន** ក៏បានឆ្លើយថា “បាទ ខ្ញុំយល់ ប៉ុន្តែខ្ញុំទុកពេលដើម្បីបកប្រែ អញ្ចឹងបានខ្ញុំសុខចិត្តនៅស្ងៀម” ។[២១] ព្រឹត្តិការណ៍មួយនេះ បានញ៉ាំងឲ្យមេធាវីរូបនេះស្នើដល់អង្គជំនុំជម្រះឲ្យធ្វើការណែនាំដល់សាក្សីឲ្យចៀសវាងការធ្វើអត្ថាធិប្បាយដោយលើកពីប្រវត្តិការសិក្សារបស់លោក មកឆ្លើយតបនឹងសំណួរដែលសួរ ។ ប្រធានតុលាការ បានអន្តរាគមន៍ និងបានរម្លឹកលោក **គង់ សំអុន** ឲ្យរៀបសំណួរឲ្យបានច្បាស់លាស់ ដើម្បីមានមូលដ្ឋានក្នុងការឆ្លើយតបដែរ ។ ប្រធានតុលាការ ក៏បានបន្តដោយដាស់តឿនសាក្សី **ឆាំង យុ** ឲ្យស្តាប់សំណួរឲ្យបានច្បាស់ ហើយឆ្លើយតបតែនឹងសំណួរនោះជាការស្រេច ។ ប្រធានតុលាការបានសង្កត់ធ្ងន់ថា “ចំពោះបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងបុគ្គលភាពនេះ គឺសូមចៀសវាង ចៀសវាងការប៉ះពាល់បុគ្គលភាពនៃបុគ្គលទាំងឡាយដែលបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនេះ។ យើងព្យាយាមផ្តល់នូវសេចក្តីថ្លៃថ្នូរដល់គ្នាទៅវិញទៅមក”។[២២] ឧទាហរណ៍មួយទៀត បានកើតឡើងក្រោយពីមានការស្តែងឲ្យឃើញនូវភាពមិនប្រាកដប្រជានៃសំណួរពីភាគីសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលសួរដេញដោលសាក្សី **ឆាំង យុ** នាំឲ្យសាក្សីរូបនេះ បែរជាសួរសំណួរបកទៅព្រះរាជអាជ្ញា **ច័ន្ទ តារាស្មី** វិញ ។ ជាលទ្ធផល ប្រធានតុលាការ **និល ណុន** បានក្រើនរំឭកដល់សាក្សី **ឆាំង យុ** ពីតួនាទីខ្លួនជាសាក្សីម្នាក់ និងបានជូនដំណឹងដល់សាក្សីថា នឹងមិនត្រូវបានអនុញ្ញាតឲ្យសួរត្រឡប់ទៅកាន់ភាគីដែលកំពុងសួរដេញដោលខ្លួននោះទេ ។

## គ. បញ្ហានៃការបកប្រែ

មានបញ្ហានៃការបកប្រែខ្លះៗបានកើតឡើងក្នុងសវនាការ និងត្រូវបានភាគី ក៏ដូចជាអង្គជំនុំជម្រះបានលើកឡើងពីការព្រួយបារម្ភនូវបញ្ហានេះ ។ ជាឧទាហរណ៍ អំឡុងពេលព្រះរាជអាជ្ញា **ឌេល លីសាក់** ធ្វើការសួរដេញដោលលោក **នួន ជា** កាលពីថ្ងៃច័ន្ទ មេធាវីជាតិការពារជនជាប់ចោទរូបនេះបានកត់សម្គាល់ថា គាត់ជាមេធាវីមិនទាំងយល់ថា លោក **លីសាក់** ចង់សួរពីអ្វីផង ។ គាត់ស្នើឲ្យលោក **លីសាក់** រៀបសំណួរឲ្យបានខ្លី និងស្នើផងដែរថាការបកប្រែចេញជាភាសាខ្មែរគួរតែកុំលឿនពេក ។ លើសពីនេះ ក្នុងពេលមេធាវីតំណាងរដ្ឋប្បវេណី **ស៊ិន ស៊ីវន** ធ្វើការសួរដេញដោលជនជាប់ចោទ **នួន ជា** អង្គជំនុំជម្រះ បានរម្លឹកលោកស្រីឲ្យនិយាយឲ្យបានយឺត ដើម្បីធានាពីភាពត្រឹមត្រូវនៃការបកប្រែ និងកំណត់ត្រាប្រតិចារិក ។ ករណីសំខាន់មួយទៀតទាក់ទងនឹងបញ្ហាដូចគ្នានេះ គឺកើតឡើងនៅពេលមានការតតាំងគ្នារវាងមេធាវី **អាកទួរ វ៉េកគែន** ជាមួយនឹងសាក្សី **ឆាំង យុ** ត្រង់ចំណុចដែលមានការសួរសំណួរមួយជាដដែលៗ សូម្បីតែក្រោយពីមានការឆ្លើយតបហើយជាភាសាខ្មែរ ។ ការពិតទៅ មេធាវី **វ៉េកគែន** មានបំណងសួរសំណួរដដែលនោះជាថ្មីម្តងទៀត ព្រោះតែគាត់មិនបានស្តាប់ឮច្បាស់នូវចម្លើយរបស់សាក្សី ។ ប្រធានតុលាការ បានធ្វើអន្តរាគមន៍ដោយបានថ្លែងថា មេធាវីប្រឹក្សាប្រហែលជាអាចមានការយល់ច្រឡំខ្លួនឯងទេ ព្រោះសាក្សីបានឆ្លើយច្បាស់លាស់ហើយ។[២៣] មេធាវី **វ៉េកគែន** បានបកស្រាយថា អាចនឹងមានការភ្លាំងភ្លាត់នៃការបកប្រែដែលថាសាក្សី **ឆាំង យុ** ឆ្លើយបានច្បាស់លាស់ហើយនោះជាភាសាខ្មែរ ព្រោះគាត់មិនទាន់បានឮ (***វ៉េកគែន** និយាយភាសាបារាំង*) ។

## ង.   តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ៣០/០១/១២ | ៩:០៤ | ១០:៣២-១០:៥៣ | ១២:០៣-១៣:៣៥ | ១៤:៤៥-១៥:១០ | ១៥:៤៣ | ៤ម៉និង២១នាទី |
| ថ្ងៃអង្គារ ៣១/០១/១២ | ៩:០៥ | ១០:២០-១០:៣៩ | - | - | ១១:៤៥ | ២ម៉និង២១នាទី |
| ថ្ងៃពុធ ០១/០២/១២ | ៩:០៨ | ១០:៣០-១០:៥២ | ១២:០៥-១៣:៣៥ | ១៤:៤៥-១៥:០៥ | ១៦:០៥ | ៤ម៉និង៤៥នាទី |
| ថ្ងៃព្រហស្បតិ៍ ០២/០២/១២ | ៩:០៥ | ១០:២១-១០:៤៨ | ១១:៥០-១៣:៣៥ | ១៤:៤៧-១៥:០៥ | ១៦:០០ | ៤ម៉និង២៥នាទី |

| | |
|---|---|
| *រយៈពេលសវនាការជាមធ្យម* | *៣ម៉ោង និង៥៨នាទី* |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | *១៥ ម៉ោង និង៥២នាទី* |
| *ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍នៃសវនាការ* | *១០៩ម៉ោង និង៤នាទី* |

***រយៈពេលសវនាការចំនួន ២៥ ថ្ងៃ អំឡុងពេល ០៧សប្តាហ៍***

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WCSC WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

---

*

*AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT Trial Monitor** was authored by Samantha Lee, Danel Mattes, Aviva Nababan,SovannaSek, Kimsan Soy,and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

---

[១] Trial Chamber. Transcript of Trial Day 23 (30 January 2012), Case No. 002/19-09-2007. E1/35.1. [hereinafter, 30 JANUARY TRANSCRIPT]. Lines 22-25; 1. 86-87.

[២] Ibid, lines 22-24. 41.

[៣] Trial Chamber. Transcript of Trial Day 24 (31 January 2012), Case No. 002/19-09-2007. E1/36.1. [hereinafter, 31JANUARY TRANSCRIPT]. Lines 4-5. 45.

[៤] See CASE 002 KRT TRIAL MONITOR Issue No. 8, Week 3 of Evidentiary Hearings (10-12 January 2012), where Nuon Chea enumerates himself, as well as these persons as the early leaders of the CPK.

[៥] 31 JANUARY TRANSCRIPT. Lines 8-10. 6.

[៦] Ibid, lines 23-24. 34.

[៧] 31 JANUARY TRANSCRIPT. Line 10. 23.

[៨] Witness clarified that "one million documents", under the DC-Cam definition, is the same as one million pages.

[៩] Trial Chamber. Transcript of Trial Day 25 (1 February 2012), Case No. 002/19-09-2007. E1/37.1. Lines 13-14. 35.

[១០] Ibid, lines 17-18. 42.

[១១] Trial Chamber. Transcript of Trial Day 26 (2 February 2012), Case No. 002/19-09-2007. [hereinafter, 2 FEBRUARY TRANSCRIPT]. E1/38.1. Lines 18-21. 13.

[១២] Witness stated that the list of names of this group of researchers was already submitted to the OCP.

[១៣] The official being referred to is Mr. Van Rith. According to Witness, Van Rith was one of the comrades of the Democratic Kampuchea and worked in its Ministry of Commerce.

[១៤] Witness explained that Professor Ben Kiernan noticed "Santebal" written on the left margin of the documents; thus, he annotated that the documents are from Santebal. "Santebal" in Khmer refers to the police or the security force.

[១៥] Trial Chamber. "Witness lists for early trial segments, deadline for filing of admissibility challenges to documents and exhibits, and response to motion E109/5" (25 October 2011). Para. 15.

[១៦] Asian International Justice Initiative. "Lessons learned from the 'Duch' Trial" (December 2009). 37. The appointed lawyer was Mr. Kong Sam Onn, who now represents Khieu Samphan in Case 002.

[១៧] Case 004 is currently under investigation before the ECCC and the list of suspects has not been publicly announced.

[១៨] 30 JANUARY TRANSCRIPT. Lines 8-9. 81.

[១៩] 2 FEBRUARY TRANSCRIPT. Lines 11-13. 45.

[២០] Ibid, line 13. 45.

[២១] Ibid, lines 13-14. 45.

[២២] Ibid, lines 8-10. 46.

[២៣] Ibid, lines 14-15. 24.